# ច្បាប់

# ស្ដីពី

# ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# ព្រះរាជក្រម

នស/រកម/០៣២៣/ ០០១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២៣ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៣ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL



ដោយក្រុម ឯកសារមន្ត្រីសាធារណៈ - https://t.me/oa_channel

# ច្បាប់

# ស្តីពី

# ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ច្បាប់នេះ កំណត់អំពីគោលការណ៍ជាមូលដ្ឋាន សម្រាប់ការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងការរៀបចំច្បាប់ហិរញ្ញវត្ថុ ជាពិសេសជំហាននីមួយៗនៃដំណើរការរៀបចំ អនុម័ត និងអនុវត្តថវិកា និងការត្រួតពិនិត្យលទ្ធផលថវិកា ព្រមទាំងការកំណត់មុខងារនិងការទទួលខុសត្រូវរបស់តួអង្គពាក់ព័ន្ធ ឱ្យសម្រេចបាននូវភាពជឿទុកចិត្តថវិកា គណនេយ្យភាពហិរញ្ញវត្ថុ ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និងគណនេយ្យភាពសមិទ្ធកម្ម ក្នុងគោលបំណងដើម្បីធានាប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងចីរភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងការទ្រទ្រង់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច កំណើនសេដ្ឋកិច្ច និងសមធមិសង្គម។

**មាត្រា២ .-**

ច្បាប់នេះ គឺជាច្បាប់គោលដែលចែកំណត់អំពីការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងមានវិសាលភាពអនុវត្តចំពោះក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងនីតិបុគ្គលដទៃទៀតដែលទទួលផលប្រយោជន៍ពីហិរញ្ញវត្ថុសាធារណៈ ព្រមទាំងចំពោះទំនាក់ទំនងនិងអន្តរសកម្មរវាងហិរញ្ញវត្ថុសាធារណៈជាតិ ហិរញ្ញវត្ថុសាធារណៈអន្តរជាតិ ហិរញ្ញវត្ថុឯកជនជាតិ និងហិរញ្ញវត្ថុឯកជនអន្តរជាតិ។

**មាត្រា៣ .-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ ត្រូវបានកំណត់និយមន័យនៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ។

## ជំពូកទី២

## គោលការណ៍គ្រឹះ ថវិកា និងធនធាននិងបន្ទុករបស់រដ្ឋ

### ផ្នែកទី១

### គោលការណ៍គ្រឹះ

**មាត្រា៤ .-**

ថវិកាត្រូវមានគោលការណ៍គ្រឹះ១០(ដប់)យ៉ាង ដែលត្រូវអនុវត្តដាច់ខាតគឺៈ

១- ភាពជាអាជ្ញា។

២- ភាពជឿទុកចិត្តបាន។

៣- ឯកត្តភាព។

៤- សកលភាព។

៥- វិសេសភាព។

៦- ចីរភាព។

៧- គណនេយ្យភាព។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

៨- ប្រសិទ្ធភាព។

៩- តម្លាភាព។

១០- សមិទ្ធកម្ម។

**មាត្រា៥ .-**

ច្បាប់ហិរញ្ញវត្ថុ រួមមាន៖

១- ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។

២- ច្បាប់ហិរញ្ញវត្ថុកែតម្រូវ។

៣- ច្បាប់ទូទាត់ថវិកា។

**មាត្រា៦ .-**

ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ គ្រោងនិងអនុញ្ញាតសម្រាប់ការិយបរិច្ឆេទមួយឆ្នាំ នូវប្រភពធនធាននិងបន្ទុករបស់រដ្ឋ អតិរេក ឬឱនភាព និងហិរញ្ញប្បទានផ្សេងៗ ដោយធានាតុល្យភាពថវិកា និងរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងអាចកំណត់នូវបទប្បញ្ញត្តិចាំបាច់ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីបម្រើឱ្យរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍសង្គម សេដ្ឋកិច្ច។

**មាត្រា៧ .-**

ច្បាប់ហិរញ្ញវត្ថុកែតម្រូវ អនុញ្ញាតឱ្យធ្វើការកែប្រែបទប្បញ្ញត្តិនៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ប្រសិនបើមានតម្រូវការចាំបាច់ ក្នុងការឆ្លើយតបទៅនឹងការផ្លាស់ប្តូរកាលៈទេសៈ មានជាអាទិ៍ គ្រោះមហន្តរាយ ការផ្លាស់ប្តូរជាគំហុកនៃស្ថានភាពម៉ាក្រូសេដ្ឋកិច្ច ឬភាពចាំបាច់ជាបន្ទាន់ផ្សេងទៀតពាក់ព័ន្ធជាសារវន្តដល់ផលប្រយោជន៍ជាតិ ដែលមិនបានរំពឹងទុកនៅក្នុងការិយបរិច្ឆេទនៃឆ្នាំថវិកា។

**មាត្រា៨ .-**

ច្បាប់ទូទាត់ថវិកា អនុម័តជារៀងរាល់ឆ្នាំ លើលទ្ធផលស្ថាពរនៃការអនុវត្តថវិកានិងហិរញ្ញវត្ថុដទៃទៀតរបស់រដ្ឋ ព្រមទាំងព័ត៌មានមិនមែនហិរញ្ញវត្ថុពាក់ព័ន្ធនៃការអនុវត្តច្បាប់ហិរញ្ញវត្ថុនៅក្នុងការិយបរិច្ឆេទនៃឆ្នាំមុន។

**មាត្រា៩ .-**

នាយករដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចេញលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួន ដើម្បីធានាដល់ការអនុវត្តច្បាប់នេះនិងច្បាប់ដូចមានចែងក្នុងមាត្រា៥ខាងលើប្រកបដោយប្រសិទ្ធភាព។

**មាត្រា១០ .-**

ក្រៅពីបទប្បញ្ញត្តិដែលមានចែងក្នុងច្បាប់នេះ ការគ្រប់គ្រងហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិជាកម្មវត្ថុនៃច្បាប់ដោយឡែក។

**មាត្រា១១ .-**

ការិយបរិច្ឆេទនៃឆ្នាំថវិកាចាប់ផ្តើមនៅថ្ងៃទី១ ខែមករា ហើយបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL



គេហទំព័រ ឯកសារផ្លូវការ - https://t.me/oa_channel

មាត្រា១២ .-

ទំនាក់ទំនងនិងអន្តរសកម្មរវាងហិរញ្ញវត្ថុសាធារណៈជាតិ ហិរញ្ញវត្ថុសាធារណៈអន្តរជាតិ ហិរញ្ញវត្ថុឯកជនជាតិ និងហិរញ្ញវត្ថុឯកជនអន្តរជាតិ សំដៅដល់ទំនាក់ទំនងដោយផ្ទាល់ឬដោយប្រយោល រវាងហិរញ្ញវត្ថុសាធារណៈជាតិ ហិរញ្ញវត្ថុសាធារណៈអន្តរជាតិ ហិរញ្ញវត្ថុឯកជនជាតិ និងហិរញ្ញវត្ថុឯកជនអន្តរជាតិ ដែលកើតឡើងតាមរយៈការគ្រប់គ្រងឬការអន្តរាគមន៍របស់រដ្ឋដោយផ្ទាល់ឬដោយប្រយោល ដើម្បីធានាចីរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ និងអភិវឌ្ឍសង្គម សេដ្ឋកិច្ច។

ទំនាក់ទំនងនិងអន្តរសកម្មទាំងនោះ មានជាអាទិ៍ ឧបករណ៍គោលនយោបាយពាក់ព័ន្ធហិរញ្ញវត្ថុ ប្រតិបត្តិការនៃការខ្ចីប្រាក់ពីគេឬការឱ្យប្រាក់គេខ្ចី ការធានារបស់រដ្ឋ ការវិនិយោគលើទ្រព្យសកម្មហិរញ្ញវត្ថុ ការវិនិយោគទុនរួមគ្នាទាំងក្នុងប្រទេសនិងក្រៅប្រទេស ការចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទាំងទ្វេភាគីនិងពហុភាគី គម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន ការបោះផ្សាយឧបករណ៍ហិរញ្ញវត្ថុ ការបង្កើតសហគ្រាសចម្រុះរដ្ឋនិងឯកជន វិភាគទានសមាជិកភាពចំពោះស្ថាប័នអន្តរជាតិឬអន្តររដ្ឋាភិបាល ការធ្វើសម្បទានផ្នែកសារពើពន្ធនិងមិនមែនសារពើពន្ធ ការប្រើប្រាស់មូលនិធិបម្រុងហិរញ្ញវត្ថុរបស់រដ្ឋ និងការអនុវត្តកម្មវិធីពិសេសរបស់រាជរដ្ឋាភិបាល ដើម្បីធ្វើអន្តរាគមន៍ដោះស្រាយបញ្ហាវិបត្តិសេដ្ឋកិច្ចនិងសង្គម។

ទំនាក់ទំនងនិងអន្តរសកម្មដែលមានចែងខាងលើ ត្រូវគ្រប់គ្រងដោយបទប្បញ្ញត្តិនៃច្បាប់នេះ ព្រមទាំងបទប្បញ្ញត្តិច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀតជាធរមាន។

មាត្រា១៣ .-

ការគ្រប់គ្រង ការរៀបចំ ការអនុវត្ត ការតាមដាន ការត្រួតពិនិត្យលើការអនុវត្តចំណូលនិងចំណាយថវិកាជាតិ និងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុនិងគណនេយ្យនៃថវិកាជាតិ ព្រមទាំងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ត្រូវប្រើប្រាស់និងឆ្លុះបញ្ចាំងក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតែមួយគត់។ វិធាននិងនីតិវិធីរួមក្នុងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចផ្ញើឯកសារផ្លូវការឬមិនទាន់ផ្លូវការ មានជាអាទិ៍ សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំនិងសំណុំឯកសារភ្ជាប់ ព្រមទាំងសេចក្តីព្រាងច្បាប់ទូទាត់ថវិកានិងសំណុំឯកសារភ្ជាប់ ជាទម្រង់លាយលក្ខណ៍អក្សរយ៉ាងច្រើនចំនួន៥(ប្រាំ)ច្បាប់ ក្រៅពីនេះ ជាទម្រង់ឌីជីថលជូនទីស្តីការគណៈរដ្ឋមន្ត្រីសម្រាប់កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រសួង ស្ថាប័នពាក់ព័ន្ធ និងស្ថាប័ននីតិប្បញ្ញត្តិ។

មាត្រា១៤ .-

មន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈនៃក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានភារកិច្ចអនុវត្តការងារហិរញ្ញវត្ថុសាធារណៈ ត្រូវមានគុណវុឌ្ឍិវិជ្ជាជីវៈតាមប្រភេទមុខតំណែងការងារនីមួយៗ។ គុណវុឌ្ឍិវិជ្ជាជីវៈតាមប្រភេទមុខតំណែងការងារនីមួយៗនេះត្រូវកំណត់ដោយអនុក្រឹត្យតាមការស្នើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

## ផ្នែកទី២
## ថវិកា

**មាត្រា១៥.-**

ថវិកា សំដៅដល់ផែនការហិរញ្ញវត្ថុរបស់រដ្ឋ ដែលត្រូវបានអនុម័តនៅក្នុងច្បាប់ហិរញ្ញវត្ថុ រួមមាន ការគ្រោងចំណូលនិងចំណាយ ការខ្ចី និងការធ្វើហិរញ្ញប្បទានបំពេញតុល្យភាពថវិកា ដើម្បីសម្រេចសមិទ្ធកម្មដែលបានគ្រោងទុក។

ចំណូលទាំងអស់ ត្រូវវិភាជសម្រាប់រាល់មុខសញ្ញាចំណាយទាំងអស់។

ថវិកាដែលត្រូវបានអនុម័តក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ជាមូលដ្ឋានក្នុងការបញ្ជាចំណាយ។

ចំណូលនិងចំណាយទាំងអស់ ត្រូវកត់ត្រាក្នុងគណនីទោលរតនាគារ។

**មាត្រា១៦.-**

ថវិកាជាតិឬថវិការដ្ឋ រួមមាន ថវិកាថ្នាក់ជាតិ ថវិកាថ្នាក់ក្រោមជាតិ ឬថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ថវិកាឧបសម្ព័ន្ធ និងគណនីពិសេសរតនាគារ។

**មាត្រា១៧.-**

ថវិកាថ្នាក់ជាតិ សំដៅដល់ថវិការបស់ក្រសួង ស្ថាប័ន ដែលរួមមាន ថវិការដ្ឋបាលកណ្តាល ថវិកាគ្រឹះស្ថានសាធារណៈរដ្ឋបាល និងថវិកាមន្ទីរជំនាញក្រោមឱវាទ ព្រមទាំងថវិកាអង្គភាពសាធារណៈប្រហាក់ប្រហែល។

ថវិកាថ្នាក់ជាតិ ត្រូវគ្រោង អនុញ្ញាត និងអនុវត្ត តាមវិធាននិងនីតិវិធីដូចមានកំណត់ក្នុងច្បាប់នេះ។

**មាត្រា១៨.-**

ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅដល់ថវិការដ្ឋបាលរាជធានី ខេត្ត ថវិការដ្ឋបាលក្រុង ស្រុក និងថវិការដ្ឋបាលឃុំ ព្រមទាំងថវិការដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធផ្សេងទៀត ស្របតាមបទប្បញ្ញត្តិជាធរមាន។

ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវគ្រោង អនុញ្ញាត និងអនុវត្ត តាមវិធាននិងនីតិវិធីដូចមានកំណត់ក្នុងច្បាប់នេះ និងច្បាប់ពាក់ព័ន្ធការគ្រប់គ្រងហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា១៩.-**

ថវិកាឧបសម្ព័ន្ធនៅថ្នាក់ជាតិ អនុវត្តចំពោះអង្គភាពរដ្ឋមិនមានបុគ្គលភាពគតិយុត្ត ដែលធ្វើប្រតិបត្តិការមានលក្ខណៈឧស្សាហកម្មនិងពាណិជ្ជកម្មជាចម្បង ដោយអនុញ្ញាតឱ្យមានចំណូលដោយឡែកសម្រាប់ចំណាយជាក់លាក់។ ថវិកាឧបសម្ព័ន្ធត្រូវបង្កើតនិងលុបដោយច្បាប់ហិរញ្ញវត្ថុ។ កិច្ចប្រតិបត្តិការនៃថវិកាឧបសម្ព័ន្ធត្រូវគ្រោង អនុញ្ញាត និងអនុវត្ត ក្នុងលក្ខខណ្ឌដូចគ្នាទៅនឹងកិច្ចប្រតិបត្តិការនៃថវិកាថ្នាក់ជាតិដែរ។ ការបង្វែរឥណទានថវិការវាងថវិកាឧបសម្ព័ន្ធនិងប្រភេទថវិកាដទៃទៀត មិនត្រូវអនុញ្ញាតឡើយ។ វិធាននិងនីតិវិធីនៃការគ្រប់គ្រងថវិកាឧបសម្ព័ន្ធត្រូវកំណត់ដោយអនុក្រឹត្យ។

ថវិកាឧបសម្ព័ន្ធនៅរដ្ឋបាលថ្នាក់ក្រោមជាតិ អនុវត្តចំពោះអង្គភាពរដ្ឋមិនមានបុគ្គលភាពគតិយុត្ត ដែលធ្វើប្រតិបត្តិការសេវាសាធារណៈមានលក្ខណៈឧស្សាហកម្ម ពាណិជ្ជកម្ម និងរដ្ឋបាល ដោយអនុញ្ញាតឱ្យមានចំណូលដោយឡែកសម្រាប់ចំណាយជាក់លាក់។ ថវិកាឧបសម្ព័ន្ធនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបង្កើតនិងលុបដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ កិច្ចប្រតិបត្តិការនៃថវិកាឧបសម្ព័ន្ធនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវគ្រោង អនុញ្ញាត និងអនុវត្ត ក្នុងលក្ខខណ្ឌដូចគ្នាទៅនឹងកិច្ចប្រតិបត្តិការនៃថវិការដ្ឋបាលថ្នាក់ក្រោមជាតិដែរ។ ការបង្វែរ



រៀបរៀងដោយ ឆានែលមន្ត្រីសាធារណៈ - https://t.me/oa_channel

ឥណទានថវិការវាងថវិកាឧបសម្ព័ន្ធ និងប្រភេទថវិកាដទៃទៀតនៅរដ្ឋបាលថ្នាក់ក្រោមជាតិ មិនត្រូវអនុញ្ញាតឡើយ។
វិធាននិងនីតិវិធីនៃការគ្រប់គ្រងថវិកាឧបសម្ព័ន្ធនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២០ .-**

គណនីពិសេសរតនាគារ អនុវត្តចំពោះអង្គភាពរដ្ឋមិនមានបុគ្គលភាពគតិយុត្តដែលធ្វើប្រតិបត្តិការមានលក្ខណៈរដ្ឋបាលជាចម្បង សម្រាប់បម្រើដល់ការអនុវត្តគោលនយោបាយឬការបំពេញបេសកកម្មជាក់លាក់ណាមួយរបស់រាជរដ្ឋាភិបាល ដោយអនុញ្ញាតឱ្យមានចំណូលដោយឡែកសម្រាប់ចំណាយជាក់លាក់។ គណនីពិសេសរតនាគារត្រូវបង្កើតនិងលុបដោយច្បាប់ហិរញ្ញវត្ថុ។

កិច្ចប្រតិបត្តិការនៃគណនីពិសេសរតនាគារ ត្រូវគ្រោង អនុញ្ញាត និងអនុវត្ត ក្នុងលក្ខខណ្ឌដូចគ្នាទៅនឹងកិច្ចប្រតិបត្តិការនៃថវិកាថ្នាក់ជាតិដែរ។ ការបង្វែរឥណទានថវិការវាងគណនីពិសេសរតនាគារនិងប្រភេទថវិកាដទៃទៀតមិនត្រូវអនុញ្ញាតឡើយ។

វិធាននិងនីតិវិធីនៃការគ្រប់គ្រងគណនីពិសេសរតនាគារត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២១ .-**

គ្រឹះស្ថានសាធារណៈរដ្ឋបាល ជានីតិបុគ្គលនៃនីតិសាធារណៈដែលមានថវិកាស្វយ័ត។

ថវិកាគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំស្របតាមគោលបំណងគោលនយោបាយ និងកម្មវិធីដែលកំណត់ដោយក្រសួង ស្ថាប័ន ឬរដ្ឋបាលថ្នាក់ក្រោមជាតិ និងត្រូវឆ្លុះបញ្ចាំងជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួង ស្ថាប័ន ឬរដ្ឋបាលថ្នាក់ក្រោមជាតិដែលត្រូវជាអាណាព្យាបាលបច្ចេកទេស។

ប្រភពធនធានជាប្រចាំរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល រួមមាន ចំណូលផ្ទាល់ និងជាយថាហេតុមានការឧបត្ថម្ភតុល្យភាពដោយថវិការដ្ឋ និងចំណូលផ្សេងៗ។

គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវមានគណនេយ្យភាពចំពោះក្រសួង ស្ថាប័ន ឬរដ្ឋបាលថ្នាក់ក្រោមជាតិសាមីដែលជាអាណាព្យាបាលបច្ចេកទេស និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលជាអាណាព្យាបាលហិរញ្ញវត្ថុ ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

កិច្ចប្រតិបត្តិការថវិកានៃគ្រឹះស្ថានសាធារណៈរដ្ឋបាលនៅថ្នាក់ជាតិ ត្រូវគ្រោង អនុញ្ញាត និងអនុវត្តជាទូទៅក្នុងលំនាំដូចគ្នាទៅនឹងកិច្ចប្រតិបត្តិការនៃថវិកាថ្នាក់ជាតិដែរ។ កិច្ចប្រតិបត្តិការថវិកានៃគ្រឹះស្ថានសាធារណៈរដ្ឋបាលនៅថ្នាក់ក្រោមជាតិ ត្រូវគ្រោង អនុញ្ញាត និងអនុវត្តជាទូទៅក្នុងលំនាំដូចគ្នាទៅនឹងកិច្ចប្រតិបត្តិការនៃថវិការដ្ឋបាលថ្នាក់ក្រោមជាតិដែរ។

វិធាននិងនីតិវិធីនៃការគ្រោងចំណូល ចំណាយ ការអនុញ្ញាត និងការអនុវត្តថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២២ .-**

ចំណាត់ថ្នាក់នៃមាតិកាថវិការដ្ឋ រួមមាន ចំណាត់ថ្នាក់សេដ្ឋកិច្ច ចំណាត់ថ្នាក់កម្មវិធី ចំណាត់ថ្នាក់រដ្ឋបាល ចំណាត់ថ្នាក់ភូមិសាស្ត្រ ចំណាត់ថ្នាក់មុខងារ ចំណាត់ថ្នាក់គម្រោង និងចំណាត់ថ្នាក់មូលនិធិ។

វិធានលម្អិតនិងការអនុវត្តចំណាត់ថ្នាក់នៃមាតិកាថវិកាខាងលើ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ផ្នែកទី៣

## ធនធាននិងបន្ទុករបស់រដ្ឋ

**មាត្រា២៣ .-**

ធនធាននិងបន្ទុករបស់រដ្ឋ រួមមាន ធនធាននិងបន្ទុកថវិកា និងធនធាននិងបន្ទុកហិរញ្ញប្បទាន។

ធនធាននិងបន្ទុកថវិកា ត្រូវបង្ហាញនៅក្នុងថវិការដ្ឋជាទម្រង់ចំណូលនិងចំណាយ។

ធនធាននិងបន្ទុកហិរញ្ញប្បទាន ត្រូវបង្ហាញក្នុងទម្រង់ជាតម្រូវការហិរញ្ញប្បទាននិងប្រភពហិរញ្ញប្បទាន។

**មាត្រា២៤ .-**

ធនធានថវិកា រួមមាន ដូចខាងក្រោម៖

១-ចំណូលសារពើពន្ធ រួមមាន ចំណូលសារពើពន្ធក្នុងស្រុក ចំណូលសារពើពន្ធលើពាណិជ្ជកម្មអន្តរជាតិ និងចំណូលសារពើពន្ធដទៃទៀត។

២-ចំណូលមិនមែនសារពើពន្ធ រួមមាន ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ចំណូលពីសហគ្រាសសាធារណៈ ភាគកម្មសាធារណៈនិងអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត ចំណូលពីសេវាសាធារណៈ ចំណូលពីការពិន័យនិងការដាក់ទណ្ឌកម្ម និងចំណូលមិនមែនសារពើពន្ធផ្សេងទៀត ដែលកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

៣-ចំណូលផ្សេងៗ រួមបញ្ចូលទាំងចំណូលបានមកពីទ្រព្យសកម្មហិរញ្ញវត្ថុរយៈពេលវែង ហិរញ្ញប្បទានឥតសំណង ការសងវិញនូវប្រាក់ឱ្យគេខ្ចី និងចំណូលផ្សេងៗដទៃទៀត។

ធនធាននីមួយៗ ត្រូវធ្វើចំណាត់ថ្នាក់ជាជំពូក គណនី អនុគណនី និងជាយថាហេតុ អាចលម្អិតជាងនេះទៀតដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា២៥ .-**

ការបង្កើត ការកែប្រែ ការលុបចោល ការយក ការកំណត់អត្រា ការកំណត់មូលដ្ឋានគិត ការលើកលែង និងការធ្វើសម្បទានពន្ធនិងអាករ ព្រមទាំងវិធាននៃការដោះស្រាយវិវាទសារពើពន្ធត្រូវកំណត់ក្នុងច្បាប់។

គ្មានបទប្បញ្ញត្តិច្បាប់ឬក្រោមច្បាប់ណាមួយ ទោះជាប្រភេទណាក៏ដោយ និងគ្មានកិច្ចព្រមព្រៀងអន្តរជាតិណាមួយ ដែលអាចធ្វើឱ្យមានការប្រែប្រួលនាំមកនូវការបាត់ចំណូលសារពើពន្ធនោះឡើយ។ ករណីខាងលើអាចប្រព្រឹត្តទៅបាន លុះត្រាតែអនុវត្តតាមទម្រង់ច្បាប់ជាធរមាន ក្រោយពីមានយោបល់ឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ការប្រមូលនិងការត្រួតពិនិត្យចំណូលសារពើពន្ធ ត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។



គេហទំព័រ ឯកសារផ្លូវការ: - https://t.me/oa_channel

មាត្រា២៦ .-

ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ត្រូវកំណត់ដោយច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ។ ការប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវបង់ចំណូលមិនមែនសារពើពន្ធទាំងអស់ចូលក្នុងគណនីទោលរតនាគារ ដោយមិនត្រូវប្រើប្រាស់ចំណែកណាមួយនៃប្រាក់ចំណូលយកទៅកាត់កងដោយត្រង់ជាមួយនឹងចំណាយឬរក្សាទុកសម្រាប់ចំណាយពិសេសណាមួយឡើយ លើកលែងតែមានគោលការណ៍អនុញ្ញាតដោយរាជរដ្ឋាភិបាល តាមការស្នើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា២៧ .-

ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ សំដៅដល់ចំណូលទទួលបានពីការចាត់ចែង ការធ្វើអាជីវកម្ម ផលបានពីសម្បទានលើទ្រព្យសម្បត្តិរដ្ឋ និងចំណូលពីទ្រព្យសម្បត្តិរដ្ឋផ្សេងទៀត ដែលកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ ត្រូវអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បំពេញមុខងារជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ។ ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងនីតិបុគ្គលសាធារណៈដទៃទៀត ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ។

មាត្រា២៨ .-

ចំណូលពីសហគ្រាសសាធារណៈ ភាគកម្មសាធារណៈ និងអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត រួមមានចំណូលដែលទទួលបានពីការបង់ភាគលាភឬអតិរេកថវិកា ភាគលើសនៃទុនទំនេរ ព្រមទាំងការបង់សាច់ប្រាក់និងសមមូលសាច់ប្រាក់ ក្រោយពីសហគ្រាសឬអង្គភាពត្រូវបានរំសាយ។ ការបង់ចំណូលចូលថវិកាជាតិរបស់សហគ្រាសសាធារណៈ ភាគកម្មសាធារណៈ និងអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត ត្រូវកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានសិទ្ធិសម្រេចក្នុងការកំណត់ឱ្យសហគ្រាសសាធារណៈនិងអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត ធ្វើការបង់មួយចំណែកឬទាំងអស់នូវភាគលើសនៃទុនទំនេរ ចូលថវិកាជាតិ ក្នុងករណីពិនិត្យឃើញថាសហគ្រាសសាធារណៈឬអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត ពុំមានតម្រូវការចាំបាច់ក្នុងការវិនិយោគ ឬធ្វើការអភិវឌ្ឍសហគ្រាសសាធារណៈ ឬអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀតនោះទេ។

មាត្រា២៩ .-

ចំណូលពីសេវាសាធារណៈ សំដៅដល់ចំណូលដែលប្រមូលបានពីការបង់កម្រៃនៃការប្រើប្រាស់សេវាសាធារណៈពីរូបវន្តបុគ្គលឬនីតិបុគ្គល សម្រាប់សេវាបង់ថ្លៃរបស់រដ្ឋ។ ការផ្តល់សេវាសាធារណៈនិងការប្រមូលចំណូលពី

សេវាសាធារណៈ ត្រូវអនុវត្តដោយក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ក្នុងគោលដៅបម្រើផលប្រយោជន៍ទូទៅ។ ក្រោមការអនុញ្ញាតរបស់រាជរដ្ឋាភិបាល សេវាសាធារណៈអាចត្រូវបានផ្តល់ដោយភាគីឯកជន តាមរយៈកិច្ចសន្យាដែលធ្វើឡើងរវាងភាគីឯកជននិងក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល ឬរវាងភាគីឯកជន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ឬរវាងភាគីឯកជន និងគ្រឹះស្ថានសាធារណៈរដ្ឋបាល។ កិច្ចសន្យានេះ ត្រូវមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬអង្គភាពដែលទទួលប្រតិភូកម្មពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្របតាមបទប្បញ្ញត្តិជាធរមាន។

កម្រៃសេវាសាធារណៈ ជាកម្មវត្ថុដែលត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័នសាមី។

**មាត្រា៣០.-**

លិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ មានជាអាទិ៍ កិច្ចសន្យា កិច្ចព្រមព្រៀងនិង/ឬលិខិតគតិយុត្តពាក់ព័ន្ធផ្សេងទៀត ត្រូវស្ថិតក្រោមការត្រួតពិនិត្យនិងទទួលបានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្របតាមបទប្បញ្ញត្តិជាធរមាន បើពុំនោះសោត ត្រូវចាត់ទុកជាមោឃៈ។

**មាត្រា៣១.-**

ចំណូលផ្សេងៗ ដូចមានរៀបរាប់ក្នុងចំណុច៣នៃមាត្រា២៤ ដោយពុំរួមបញ្ចូលចំណូលទាំងឡាយដែលស្ថិតក្នុងប្រភេទចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធខាងលើ ត្រូវគ្រប់គ្រងនិងអនុវត្តក្រោមការកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**មាត្រា៣២.-**

បន្ទុកថវិការបស់រដ្ឋ រួមមាន ចំណាយចរន្តនិងចំណាយមូលធន ដែលត្រូវបានបែងចែកជា៦ប្រភេទ ដូចខាងក្រោម៖

១-បន្ទុកបុគ្គលិក រួមមាន ចំណាយលើបៀវត្ស ប្រាក់បំណាច់និងប្រាក់ឧបត្ថម្ភផ្សេងៗ ប្រាក់វិភាជន៍សង្គម វិភាគទានសង្គម និងប្រាក់អត្ថប្រយោជន៍ផ្សេងៗ។

២-ចំណាយប្រតិបត្តិការ រួមមាន ចំណាយលើការទិញទំនិញ ការជួសជុលថែទាំ និងការជួលសេវា ដើម្បីទទួលបាននូវមធ្យោបាយនិងសេវាផ្សេងៗ បម្រើឱ្យសកម្មភាពរបស់រដ្ឋ។

៣-បន្ទុកហិរញ្ញវត្ថុ រួមមាន ចំណាយលើការប្រាក់ និងបន្ទុកពាក់ព័ន្ធផ្សេងៗនៃបំណុលសាធារណៈក្នុងប្រទេស និងក្រៅប្រទេស។

៤-ចំណាយវិនិយោគ រួមមាន ចំណាយលើការទទួលបាននូវទ្រព្យសកម្មរយៈពេលវែងទាំងរូបី និងអរូបី ព្រមទាំងទ្រព្យសកម្មហិរញ្ញវត្ថុរយៈពេលវែង។

៥-ការផ្ទេរ៖

- ចំណាយអន្តរាគមន៍ រួមមាន ចំណាយលើការផ្តល់អត្ថប្រយោជន៍សង្គម ចំណាយអន្តរាគមន៍ផ្នែកសង្គម សេដ្ឋកិច្ច និងវប្បធម៌
- ចំណាយឧបត្ថម្ភធន ដោយមានភ្ជាប់លក្ខខណ្ឌនិងគ្មានភ្ជាប់លក្ខខណ្ឌទៅរដ្ឋបាលថ្នាក់ក្រោមជាតិ

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL



តេលេក្រាម ឯកសារមន្ត្រីសាធារណៈ - https://t.me/oa_channel

- ចំណាយឧបត្ថម្ភធនទៅគ្រឹះស្ថានសាធារណៈរដ្ឋបាល
- ចំណាយឧបត្ថម្ភធនទៅសហគ្រាសសាធារណៈ
- ការផ្តល់អំណោយ
- ចំណាយឧបត្ថម្ភធនផ្សេងៗ។

៦-ចំណាយផ្សេងៗ រួមមាន ចំណាយលើពន្ធនិងអាករដែលបង់ដោយរដ្ឋ ចំណាយមិនទាន់បែងចែកមានមុខសញ្ញា ចំណាយមិនបានគ្រោងទុក និងចំណាយដទៃទៀត។

ប្រភេទចំណាយនីមួយៗ ត្រូវធ្វើចំណាត់ថ្នាក់ជាជំពូក គណនី អនុគណនី ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៣៣ .-**

ធនធាននិងបន្ទុកហិរញ្ញប្បទានរបស់រដ្ឋ ដែលជួយធានាបាននូវតុល្យភាពហិរញ្ញវត្ថុរបស់រដ្ឋ គឺជាលទ្ធផលនៃកិច្ចប្រតិបត្តិការ ដូចខាងក្រោមះ

១-ចលនាប្រាក់ទំនេររបស់រដ្ឋ។

២-ការគ្រប់គ្រងប្រាក់បញ្ញើរបស់និក្ខិត្តករ។

៣-ការខ្ចីប្រាក់ បំណុលប្រហាក់ប្រហែល និងហិរញ្ញប្បទានសហប្រតិបត្តិការ។

៤-ប្រតិបត្តិការសាច់ប្រាក់ផ្សេងទៀត។

**មាត្រា៣៤ .-**

កិច្ចប្រតិបត្តិការ ដែលមានចែងក្នុងមាត្រា៣៣នៃច្បាប់នេះ ត្រូវគោរពទៅតាមគោលការណ៍គ្រឹះមួយចំនួនដូចខាងក្រោមះ

១-ការវិនិយោគប្រាក់ទំនេររបស់រដ្ឋ ត្រូវអនុវត្តទៅតាមការអនុញ្ញាតជាប្រចាំឆ្នាំជាទូទៅឬការអនុញ្ញាតពិសេសណាមួយ ដែលកំណត់ដោយច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។

២-គណនីប្រាក់បញ្ញើរបស់និក្ខិត្តករមិនត្រូវមានវិបារូបន៍។

៣-ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពសាធារណៈប្រហាក់ប្រហែល ត្រូវដាក់ចូលក្នុងគណនីនៅរតនាគារជាតិជាចាំបាច់ លើកលែងតែមានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៤-ការខ្ចីប្រាក់ បំណុលប្រហាក់ប្រហែល និងហិរញ្ញប្បទានសហប្រតិបត្តិការ ត្រូវអនុវត្តស្របតាមការអនុញ្ញាតប្រចាំឆ្នាំជាទូទៅ ឬការអនុញ្ញាតពិសេសណាមួយ ដែលកំណត់ដោយច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។

ក្រៅពីប្រភពធនធាននិងបន្ទុកហិរញ្ញប្បទានដែលត្រូវគ្រប់គ្រងតាមបទប្បញ្ញត្តិច្បាប់ពាក់ព័ន្ធជាធរមាន វិធាននិងនីតិវិធីនៃការគ្រប់គ្រងធនធាននិងបន្ទុកហិរញ្ញប្បទានឯទៀតដែលមានចែងខាងលើនេះ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៣៥ .-**

មូលនិធិបម្រុងហិរញ្ញវត្ថុ គឺជាមូលនិធិប្រាក់សន្សំរបស់រដ្ឋ។ ប្រភពនៃមូលនិធិបម្រុងហិរញ្ញវត្ថុនេះ រួមមានះ

- ចំណាយប្រចាំឆ្នាំនៃថវិកាថ្នាក់ជាតិ ក្នុងទំហំពី២(ពីរ)ភាគរយ ទៅ៤(បួន)ភាគរយនៃលទ្ធផលអនុវត្តចំណាយចរន្តថវិកាថ្នាក់ជាតិមួយឆ្នាំមុនឆ្នាំកំពុងអនុវត្តថវិកា ដែលត្រូវកំណត់នៅក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ

- អតិរេកដែលអាចកើតមានពីការអនុវត្តថវិកាថ្នាក់ជាតិប្រចាំឆ្នាំ ដែលត្រូវកំណត់ដោយច្បាប់ទូទាត់ថវិកា

- ប្រភពផ្សេងៗទៀត ដែលត្រូវកំណត់ក្នុងច្បាប់ហិរញ្ញវត្ថុ។

មូលនិធិបម្រុងហិរញ្ញវត្ថុ ត្រូវបានសន្សំទុកសម្រាប់គោលដៅនៃការធ្វើអន្តរាគមន៍ដោះស្រាយបញ្ហាដែលមានសារៈសំខាន់ជាសារវន្ត នៅពេលដែលប្រទេសជាតិប្រឈមមុខនឹងវិបត្តិសេដ្ឋកិច្ច ហិរញ្ញវត្ថុ ឬគ្រោះអាសន្នបន្ទាន់នានា ជាអាទិ៍ ការឆ្លងរាលដាលនៃជំងឺកាចសាហាវនិងគ្រោះមហន្តរាយធម្មជាតិ។

មូលនិធិបម្រុងហិរញ្ញវត្ថុ អាចយកទៅវិនិយោគរយៈពេលខ្លី មធ្យម និងវែង។

មូលនិធិបម្រុងហិរញ្ញវត្ថុ ត្រូវកត់ត្រាក្នុងគណនីទោលរតនាគារ។ សមតុល្យនៃមូលនិធិបម្រុងហិរញ្ញវត្ថុ ត្រូវបានយោងបន្តពីមួយឆ្នាំទៅមួយឆ្នាំ។

ការប្រើប្រាស់មូលនិធិបម្រុងហិរញ្ញវត្ថុ ជាកម្មវត្ថុនៃការអនុម័តនៅក្នុងច្បាប់ហិរញ្ញវត្ថុ។ មូលនិធិបម្រុងហិរញ្ញវត្ថុត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់រាជរដ្ឋាភិបាល។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសេនាធិការរបស់រាជរដ្ឋាភិបាល ក្នុងការគ្រប់គ្រងនិងការចាត់ចែងមូលនិធិបម្រុងហិរញ្ញវត្ថុ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរាយការណ៍ជូនរដ្ឋសភានិងព្រឹទ្ធសភាជារៀងរាល់ឆ្នាំអំពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងមូលនិធិបម្រុងហិរញ្ញវត្ថុ។

វិធាននិងនីតិវិធីនៃការគ្រប់គ្រងមូលនិធិបម្រុងហិរញ្ញវត្ថុ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៣៦ .-**

ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ធ្វើការប៉ាន់ស្មានពីធនធាននិងបន្ទុកថវិការបស់រដ្ឋ កំណត់ជំហរគោលនយោបាយថវិកា កំណត់ពិតានចំណាយថវិកាថ្នាក់ជាតិនិងពិតានចំណាយថវិកាថ្នាក់ក្រោមជាតិ ព្រមទាំងកំណត់ពិតានតម្រូវការហិរញ្ញប្បទាន និងវាយតម្លៃហានិភ័យហិរញ្ញវត្ថុសាធារណៈ សម្រាប់រយៈពេលមធ្យម ដោយផ្អែកលើមូលដ្ឋាននៃទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ច និងអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល ដើម្បីធានាបាននូវចីរភាពហិរញ្ញវត្ថុសាធារណៈ។

ក្របខ័ណ្ឌថវិការយៈពេលមធ្យម កំណត់ពិតានចំណាយថវិការបស់ក្រសួង ស្ថាប័ន ដោយផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយអាទិភាពរបស់ក្រសួង ស្ថាប័ន និងមានសង្គតិភាពទៅនឹងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម។

ក្របខ័ណ្ឌថវិការយៈពេលមធ្យមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ កំណត់ពិតានចំណាយថវិការបស់រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ដោយផ្អែកតាមក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម។

ក្របខ័ណ្ឌថវិការយៈពេលមធ្យមទាំងពីរខាងលើ ត្រូវប្រើជាមូលដ្ឋានក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំដើម្បីសម្រេចសមិទ្ធកម្មដែលបានគ្រោងទុក។

**មាត្រា៣៧ .-**

ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវវិភាជឥណទានថវិកាទៅតាមក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល តាមមុខងារនិងតាមប្រភេទចំណាយ ព្រមទាំងឆ្លុះបញ្ចាំងឱ្យឃើញនូវថវិកាឧបសម្ព័ន្ធនៅថ្នាក់ជាតិ គណនីពិសេសរតនាគារ និងគ្រឹះស្ថានសាធារណៈរដ្ឋបាលនៅថ្នាក់ជាតិ។



តេលេក្រាម ឯកសារមន្ត្រីសាធារណៈ - https://t.me/oa_channel

ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវវិភាជឥណទានថវិកាដល់រដ្ឋបាលរាជធានី ខេត្ត តាមកម្មវិធី និងប្រភេទចំណាយ និងឥណទានថវិកាជាកញ្ចប់ដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ព្រមទាំងឆ្លុះបញ្ចាំងឱ្យឃើញពីថវិកាឧបសម្ព័ន្ធនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងថវិកាគ្រឹះស្ថានសាធារណៈរដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា៣៨ .-**

ឥណទានថវិកាដែលបានអនុម័តក្នុងច្បាប់ហិរញ្ញវត្ថុ ត្រូវបែងចែកជូនក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល តាមកម្មវិធី និងប្រភេទចំណាយ ដើម្បីរួមចំណែកសម្រេចគោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល និងគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាល។

ការបែងចែកឥណទានថវិកាជូនក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល កម្រិតកម្មវិធី និងកម្រិតជំពូកនៃចំណាត់ថ្នាក់មាតិកាថវិកា ត្រូវកំណត់ដោយអនុក្រឹត្យ។

ការបែងចែកឥណទានថវិកាលម្អិតតាមអនុកម្មវិធីនិងចង្កោមសកម្មភាព និងចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចេញប្រកាសដាក់ឱ្យប្រើប្រាស់សៀវភៅថវិកាស្តីពីការបែងចែកឥណទានថវិកាក្រោមកម្រិតកម្មវិធី និងក្រោមកម្រិតជំពូកនៃចំណាត់ថ្នាក់មាតិកាថវិកា ឱ្យបានមុនថ្ងៃទី១ ខែមករា នៃឆ្នាំអនុវត្តថវិកា។

ចំណាយមិនទាន់បែងចែកមានមុខសញ្ញា ដែលមានចែងក្នុងចំណុចទី៦នៃមាត្រា៣២នៃច្បាប់នេះ គឺជាមុខចំណាយដែលមានការកំណត់ច្បាស់លាស់ដោយច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ហើយជាកម្មវត្ថុនៃការផ្ទេរដោយអនុក្រឹត្យទៅតាមគោលដៅនៃមុខចំណាយ នៅពេលដែលឥណទានថវិកានោះត្រូវបានអនុម័ត។

ចំណាយមិនបានគ្រោងទុក ដែលមានចែងក្នុងចំណុចទី៦នៃមាត្រា៣២នៃច្បាប់នេះ មិនត្រូវបែងចែកឱ្យទៅក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិឡើយ។ ឥណទានថវិកានៃចំណាយមិនបានគ្រោងទុក ត្រូវបានអនុញ្ញាតសម្រាប់ចំណាយទាំងឡាយណាដែលមិនទាន់អាចកំណត់ជាក់លាក់ជាមុនបាន មានជាអាទិ៍ ភាពបន្ទាន់ឬចំណាយដែលពាក់ព័ន្ធនឹងគ្រោះអាសន្ននិងព្រឹត្តិការណ៍ផ្សេងៗដែលកើតឡើងជាយថាហេតុ សម្រាប់វិភាជឡើងវិញទៅក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ នៅពេលដែលឥណទានថវិកានោះត្រូវបានអនុម័ត។

**មាត្រា៣៩ .-**

ឥណទានថវិកាមានពីរប្រភេទ គឺឥណទានកំហិតកំណត់ និងឥណទានប៉ាន់ប្រមាណ។

ឥណទានកំហិតកំណត់ គឺត្រូវបានផ្តល់ជាការសន្យានិងការអនុញ្ញាតត្រឹមកម្រិតខ្ពស់បំផុតមួយ ដែលចំណាយប្រភេទនេះត្រូវបានកំណត់ជាមុន។ ចំណាយបែបនេះអាចបង្កើនបានតែតាមរយៈច្បាប់ហិរញ្ញវត្ថុកែតម្រូវតែមួយប៉ុណ្ណោះ។

ឥណទានប៉ាន់ប្រមាណ គឺត្រូវបានអនុញ្ញាតសម្រាប់ចំណាយចាំបាច់ និងក្នុងករណីដែលការគ្រោងមិនគ្រប់គ្រាន់នៅដំណាក់កាលបន្ទាប់ពីការអនុម័តថវិកា។ ចំណាយនៃឥណទានប្រភេទនេះ អាចត្រូវបានប្រើប្រាស់លើសពីឥណទានដែលបានគ្រោងនៅក្នុងកម្មវិធីនិងជំពូកថវិកាពាក់ព័ន្ធ។ ឥណទានប្រភេទនេះ កើតមានលើបំណុល

សាធារណៈ វិភាគទានសមាជិកភាពចំពោះស្ថាប័នអន្តរជាតិឬអន្តររដ្ឋាភិបាល អន្តរាគមន៍គាំពារសង្គម និងចំណាយផ្សេងទៀតដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ឥណទានបៀវត្សនិងប្រាក់បំណាច់របស់បុគ្គលិក អាចអនុញ្ញាតឱ្យមានកម្រិតលម្អៀងលើការគ្រោងក្នុងរង្វង់នៃចំនួនបុគ្គលិកតាមក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានកំណត់នៅក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។ ការបង្កើនឥណទានបៀវត្សនិងប្រាក់បំណាច់របស់បុគ្គលិក ដោយសារការកើនឡើងនៃចំនួនបុគ្គលិកនៅក្នុងឆ្នាំអនុវត្តថវិកា មិនត្រូវបានអនុញ្ញាតទេ។ ពិតានចំនួនបុគ្គលិកតាមក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។ ក្នុងករណីមានតម្រូវការពិសេស ចាំបាច់ និងបន្ទាន់ រាជរដ្ឋាភិបាលអាចបង្កើនពិតានចំនួនបុគ្គលិក ព្រមទាំងបង្កើនឥណទានបៀវត្សនិងប្រាក់បំណាច់របស់បុគ្គលិក ស្របទៅនឹងការបង្កើនចំនួនបុគ្គលិក ដែលការបង្កើននេះ ជាកម្មវត្ថុនៃការអនុម័តដោយច្បាប់ទូទាត់ថវិកានៃឆ្នាំអនុវត្តថវិកា។

**មាត្រា៤០ .-**

ឥណទានចំណាយចរន្ត ត្រូវបែងចែកជាឥណទានសម្រាប់ការអនុវត្តកម្មវិធីដែលបានអនុម័ត និងឥណទានសម្រាប់អនុវត្តវិធានការថ្មីនៃកម្មវិធីនោះ។

ឥណទានសម្រាប់ការអនុវត្តកម្មវិធីដែលបានអនុម័ត រួមមាន ឥណទានដែលបានកំណត់នៅក្នុងចំណាយប្រតិបត្តិការឆ្នាំមុន ដកទាយជ្ជទាន និងដកឥណទានសម្រាប់សកម្មភាពការងារដែលនឹងមិនកើតឡើងវិញនៅក្នុងឆ្នាំគ្រោងថវិកា បូកបន្ថែមឥណទានសម្រាប់ការកែប្រែតាមស្ថានភាពជាក់ស្តែង។

ឥណទានសម្រាប់ការអនុវត្តកម្មវិធីដែលបានអនុម័ត ត្រូវស្ថិតក្នុងកម្រិតអប្បបរមាចាំបាច់ដែលត្រូវការសម្រាប់ដំណើរការសកម្មភាពការងារចាំបាច់នៅក្នុងលក្ខខណ្ឌនៃឆ្នាំមុន។

ការកែប្រែតាមស្ថានភាពជាក់ស្តែង ត្រូវគិតអំពីផលប៉ះពាល់ដែលបានកើតឡើងនៅក្នុងឆ្នាំមុន និងដែលអាចកើតឡើងនៅក្នុងឆ្នាំបន្តបន្ទាប់ ក្នុងក្របខ័ណ្ឌថវិការយៈពេលមធ្យម។

វិធានការថ្មីនៃកម្មវិធី គឺជាវិធានការដែលទាក់ទងទៅនឹងការសម្រេចទាំងឡាយណាដែលនាំឱ្យមានផលប៉ះពាល់ហិរញ្ញវត្ថុបន្ថែមទៀតទៅលើថវិកា។

ឥណទានថវិកាសម្រាប់អនុវត្តកម្មវិធី ត្រូវមានការពន្យល់ពីភាពចាំបាច់ ភាពសមស្រប និងមូលដ្ឋានគណនាក្នុងទិសដៅសម្រេចបាននូវសមិទ្ធកម្មដែលបានគ្រោងទុក។

វិធាននិងនីតិវិធីនៃការបែងចែកឥណទានចំណាយចរន្ត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៤១ .-**

ឥណទានចំណាយមូលធន គឺជាឥណទានវិនិយោគដែលចែកចេញជាឥណទានភ្ជាប់សន្យា និងឥណទានទូទាត់។ ឥណទានវិនិយោគ កំណត់លើគម្រោងឬកម្មវិធីវិនិយោគ ទាំងឡាយដែលរដ្ឋបានផ្តួចផ្តើមនៅក្នុងឆ្នាំ និងគណនាតម្រូវការចំណាយសរុប ដោយមានសង្គតិភាពទៅនឹងផែនការគម្រោងវិនិយោគរយៈពេលមធ្យម។



តេលេក្រាម ឯកសារមន្ត្រីសាធារណៈ - https://t.me/oa_channel

ឥណទានភ្ជាប់សន្យា ជាឥណទានកំហិតកំណត់ដែលត្រូវបានអនុញ្ញាតនៅក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ សម្រាប់ឱ្យរាជរដ្ឋាភិបាលធ្វើការធានាចំណាយសម្រាប់ប្រតិបត្តិការទាំងស្រុងនៃគម្រោងឬកម្មវិធីវិនិយោគដែលបានគ្រោងដោយមិនអនុញ្ញាតឱ្យមានការគ្រោងឥណទានបន្ថែមសម្រាប់បញ្ចប់នោះទេ។ ឥណទានភ្ជាប់សន្យានេះត្រូវមានសង្គតិភាពទៅនឹងក្របខ័ណ្ឌថវិការយៈពេលមធ្យម និងធានាបាននូវចីរភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។

ឥណទានទូទាត់ ត្រូវប្រើសម្រាប់ចេញបញ្ជាចំណាយដែលជាបន្ទុករបស់រដ្ឋទៅតាមលក្ខខណ្ឌទូទាត់នៃកិច្ចសន្យាគម្រោងវិនិយោគ និងនៅក្នុងកម្រិតនៃឥណទានភ្ជាប់សន្យា។

ឥណទានភ្ជាប់សន្យានិងឥណោទានទូទាត់ ត្រូវដាក់នៅក្រោមអាណាប័ក សម្រាប់ចំណាយចាំបាច់ក្នុងការអនុវត្តគម្រោងវិនិយោគ ដែលបានកំណត់នៅក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។

**មាត្រា៤២ .-**

ឥណទានភ្ជាប់សន្យាអាចមានតម្លៃគ្មានកំណត់ពេល។ ឥណទាននេះ ត្រូវបានយោងពីមួយឆ្នាំទៅមួយឆ្នាំ រហូតដល់ការលុបជាយថាហេតុ។ ឥណទានទូទាត់ដែលមិនបានប្រើនៅពេលបិទការគ្រប់គ្រង(បញ្ចប់ឆ្នាំ) ត្រូវបានលុបនិងអាចអនុញ្ញាតឥណទានថ្មីសម្រាប់ឆ្នាំបន្ទាប់។

**មាត្រា៤៣ .-**

គម្រោងឬកម្មវិធីវិនិយោគរបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលរាជធានី ខេត្តដែលមិនទាន់បញ្ចប់នៅឆ្នាំអនុវត្ត ឥណទានទូទាត់នៃចំណាយមូលធនដែលមិនទាន់បានប្រើប្រាស់នៅពេលបិទការគ្រប់គ្រង(បញ្ចប់ឆ្នាំ) អាចអនុញ្ញាតឱ្យយោងជាឥណទានទូទាត់ទៅឆ្នាំបន្ទាប់បាន សម្រាប់បញ្ចប់គម្រោងឬកម្មវិធីវិនិយោគចាំបាច់។ ឥណទានយោងទៅឆ្នាំបន្ទាប់នេះ ត្រូវសម្រេចដោយអនុក្រឹត្យតាមការស្នើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ យ៉ាងយូរនៅត្រឹមថ្ងៃទី៣១ ខែមករា នៅឆ្នាំបន្ទាប់។

ឥណទានទូទាត់ដែលអនុញ្ញាតឱ្យយោងទៅឆ្នាំបន្ទាប់ ត្រូវកម្រិតមិនឱ្យលើសពី១០(ដប់)ភាគរយ រៀងៗគ្នានៃឥណទានចំណាយវិនិយោគថ្នាក់ជាតិប្រចាំឆ្នាំ និងឥណទានចំណាយវិនិយោគនៃរដ្ឋបាលរាជធានី ខេត្តប្រចាំឆ្នាំ។ ឥណទានទូទាត់ដែលអនុញ្ញាតឱ្យយោងពីឆ្នាំមុនដែលមិនបានប្រើប្រាស់ក្នុងឆ្នាំបន្ទាប់ ត្រូវទុកជាមោឃៈនៅក្នុងច្បាប់ទូទាត់ថវិកានៃឆ្នាំបន្ទាប់។

ដោយឡែក ការយោងឥណទានទូទាត់ទៅឆ្នាំបន្ទាប់សម្រាប់គម្រោងឬកម្មវិធីវិនិយោគរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ឥណទានដែលអនុញ្ញាតឱ្យយោងខាងលើនេះ ជាកម្មវត្ថុនៃការកត់ត្រាក្នុងច្បាប់ទូទាត់ថវិកានៅឆ្នាំបន្ទាប់។

វិធាន លក្ខណវិនិច្ឆ័យ និងនីតិវិធីនៃការអនុញ្ញាតឱ្យយោងឥណទានទូទាត់ទៅឆ្នាំបន្ទាប់ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៤៤ .-**

ឥណទានវិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេស គឺជាឥណទានប៉ាន់ប្រមាណ ហើយពុំអាចធ្វើជាកម្មវត្ថុនៃនិយ័តភាពទៅប្រភេទចំណាយណាមួយផ្សេងទៀតបានឡើយ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មាត្រា៤៥ .-

គ្មានវិធានការជាបទប្បញ្ញត្តិច្បាប់ បទបញ្ជា ឬរដ្ឋបាលណាមួយ អាចត្រូវបានអនុម័តទទួលស្គាល់ឬសម្រេចបានទេ ប្រសិនបើតម្រូវការចំណាយនៃបន្ទុកថ្មីដែលនឹងកើតឡើងនោះ មិនត្រូវបានវាយតម្លៃ ព្យាករ និងអនុញ្ញាតមុននិងក្នុងពេលគ្រោង និងកំណត់ដោយច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។

មាត្រា៤៦ .-

ចំណូល ត្រូវប្រមូល កត់ត្រា និងបង់ទាំងស្រុងចូលគណនីទោលរតនាគារ ហើយមិនត្រូវយកទៅកាត់កងដោយត្រង់ជាមួយចំណាយណាមួយឡើយ។

ចំណូលទាំងមូល ត្រូវវិភាជសម្រាប់រាល់មុខសញ្ញាចំណាយទាំងអស់។ ប៉ុន្តែ ចំណូលខ្លះអាចត្រូវវិភាជសម្រាប់តែមុខសញ្ញាចំណាយជាក់ស្តែងណាមួយក្នុងទម្រង់និងក្រោមលក្ខខណ្ឌ ដែលត្រូវកំណត់ដោយច្បាប់។ ការវិភាជទាំងនេះ ត្រូវរៀបចំតាមទម្រង់ថវិកាឧបសម្ព័ន្ធ ឬគណនីពិសេសរតនាគារ។

ការបង្កើនដោយអាណាប័កន្ទរទឹកប្រាក់នៃឥណទានដែលបានអនុម័ត ដោយសំអាងលើប្រាក់ចំណូលពិសេសណាមួយ ត្រូវបានហាមឃាត់ដាច់ខាត។

## ផ្នែកទី៤
## សិទ្ធិអំណាចនិងការទទួលខុសត្រូវ

មាត្រា៤៧ .-

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភារកិច្ចទទួលខុសត្រូវក្នុងការគ្រប់គ្រងចំណូលនិងចំណាយថវិកា ការខ្ចីប្រាក់ពីគេ ការឱ្យប្រាក់គេខ្ចី និងការធានារបស់រដ្ឋ ដែលត្រូវបានអនុញ្ញាតដោយច្បាប់។

គោលបំណង ពិតាន និងលក្ខខណ្ឌផ្នែកហិរញ្ញវត្ថុនៃការខ្ចីប្រាក់ពីគេ ការឱ្យប្រាក់គេខ្ចី និងការធានារបស់រដ្ឋ ត្រូវកំណត់នៅក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។

មាត្រា៤៨ .-

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការរៀបចំ ការអនុវត្ត ការតាមដាន និងការគ្រប់គ្រងក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភារកិច្ចផ្តល់របាយការណ៍អំពីស្ថានភាពក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ជូនរដ្ឋសភានិងព្រឹទ្ធសភាពីរដងក្នុងមួយឆ្នាំ គឺនៅពាក់កណ្តាលឆ្នាំ និងនៅពេលពិភាក្សាអនុម័តសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។

មាត្រា៤៩ .-

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភារកិច្ចដឹកនាំការគោរពនិងការរក្សាវិន័យហិរញ្ញវត្ថុសាធារណៈ ព្រមទាំងពង្រឹងប្រសិទ្ធភាពថវិកាទាំងកម្រិតវិភាជន៍ និងកម្រិតអនុវត្តន៍ តាមរយៈការរៀបចំនិងអនុវត្តក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ការរៀបចំក្របខ័ណ្ឌថវិការយៈពេលមធ្យម ការគោរពច្បាប់ហិរញ្ញវត្ថុ និងតាមដានការអនុវត្តថវិកា ដោយមានយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃជាប្រចាំលើការគ្រប់គ្រងថវិកា។



គេហទំព័រ ឯកសារមន្ត្រីសាធារណៈ - https://t.me/oa_channel

**មាត្រា៥០.-**

រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ មានភារកិច្ចទទួលខុសត្រូវក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ការគ្រប់គ្រងថវិកា និងការត្រួតពិនិត្យការអនុវត្តថវិការបស់ខ្លួន ជាពិសេសត្រូវមានគណនេយ្យភាពចំពោះការកំណត់និងលទ្ធផលនៃការអនុវត្តគោលនយោបាយ នៅក្នុងវិស័យនិងដែនសមត្ថកិច្ចរបស់ខ្លួន ដែលស្របទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៣
## ការរៀបចំនិងការអនុម័តថវិកា
### ផ្នែកទី១
### ក្របខ័ណ្ឌនៃការរៀបចំថវិកា

**មាត្រា៥១.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចេញសារាចរស្តីពីប្រតិទិនលម្អិតនៃការរៀបចំថវិកាប្រចាំឆ្នាំនៅអំឡុងពាក់កណ្តាលខែមករា។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំសេចក្តីព្រាងសារាចររបស់រាជរដ្ឋាភិបាលស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកានិងគម្រោងថវិកាប្រចាំឆ្នាំ ដោយផ្អែកលើក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម និងក្របខ័ណ្ឌថវិការយៈពេលមធ្យម ដែលបានកំណត់ដោយរាជរដ្ឋាភិបាល ដើម្បីដាក់ជូននាយករដ្ឋមន្ត្រីពិនិត្យនិងសម្រេច នៅដើមខែឧសភា ដោយមានបញ្ជាក់នូវទម្រង់ បែបបទ និងនីតិវិធីនៃការរៀបចំគម្រោងថវិកា ព្រមទាំងឯកសារពាក់ព័ន្ធដែលត្រូវភ្ជាប់ជាមួយ។

រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ប្រធានគ្រប់អង្គភាពសាធារណៈប្រហាក់ប្រហែល និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវរៀបចំផែនការយុទ្ធសាស្ត្រថវិកានិងគម្រោងថវិកាប្រចាំឆ្នាំ ដោយអនុលោមតាមសារាចររបស់រាជរដ្ឋាភិបាលដូចមានចែងខាងលើ និងត្រូវផ្ញើជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅអំឡុងពាក់កណ្តាលខែមិថុនា។

សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវដាក់ឆ្លងគណៈរដ្ឋមន្ត្រី ពិនិត្យ និងសម្រេចនៅក្នុងអំឡុងពាក់កណ្តាលខែតុលា។ បន្ទាប់ពីបានពិនិត្យនិងសម្រេចរួចហើយ រាជរដ្ឋាភិបាលត្រូវបញ្ជូនសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំនិងសំណុំឯកសារពាក់ព័ន្ធផ្សេងទៀត ជូនទៅរដ្ឋសភា យ៉ាងយូរនៅសប្តាហ៍ទី៤ នៃខែតុលា ដើម្បីពិនិត្យនិងអនុម័តមុននឹងបញ្ជូនសេចក្តីព្រាងច្បាប់នេះជូនទៅព្រឹទ្ធសភា យ៉ាងយូរនៅសប្តាហ៍ទី១នៃខែធ្នូ ដើម្បីពិនិត្យ ហើយឱ្យយោបល់មុនថ្ងៃទី២០ ខែធ្នូ និងប្រកាសឱ្យប្រើដោយព្រះរាជក្រម ព្រមទាំងរៀបចំបែបបទអនុវត្តឱ្យបានចប់សព្វគ្រប់ យ៉ាងយូរត្រឹមថ្ងៃទី៣១ ខែធ្នូ។

ក្នុងករណីមានការស្នើសុំពីគណៈកម្មការជំនាញពាក់ព័ន្ធរបស់រដ្ឋសភា ក្រោមការសម្របសម្រួលរបស់គណៈកម្មការទទួលបន្ទុកហិរញ្ញវត្ថុនៃរដ្ឋសភា សមាជិករាជរដ្ឋាភិបាលដែលទទួលបន្ទុកដឹកនាំគ្រប់គ្រងក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល មានភារកិច្ចដឹកនាំមន្ត្រីជំនាញពាក់ព័ន្ធដើម្បីឆ្លើយបំភ្លឺអំពីគោលបំណងគោលនយោបាយ និងកម្មវិធី ព្រមទាំងរបាយការណ៍សមិទ្ធកម្មនៃកម្មវិធីក្រោមសមត្ថកិច្ចក្រសួង ស្ថាប័ន និងអង្គភាព

សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវផ្សព្វផ្សាយជាសាធារណៈក្នុងរយៈពេល១សប្តាហ៍ បន្ទាប់ពីបញ្ជូនទៅរដ្ឋសភា និងផ្សព្វផ្សាយជាសាធារណៈក្នុងរយៈពេល២សប្តាហ៍បន្ទាប់ពីច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំនេះចូលជាធរមាន។

ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម និងក្របខ័ណ្ឌថវិការយៈពេលមធ្យម ត្រូវបញ្ជូនទៅរដ្ឋសភា និងផ្សព្វផ្សាយនៅក្នុងខែមេសា បន្ទាប់ពីទទួលបានការសម្រេចដោយគណៈរដ្ឋមន្ត្រី។

ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម និងក្របខ័ណ្ឌថវិការយៈពេលមធ្យម អាចត្រូវបានធ្វើបច្ចុប្បន្នកម្មមុននឹងបញ្ជូនភ្ជាប់ទៅនឹងសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំទៅរដ្ឋសភា។

## ផ្នែកទី២
## ដំណើរការនៃការរៀបចំ និងការអនុម័តថវិកា

**មាត្រា៥២ .-**

ការរៀបចំថវិកា ត្រូវគោរពបទប្បញ្ញត្តិដែលមានចែងនៅក្នុងមាត្រា៤ មាត្រា៦ និងមាត្រា១៥នៃច្បាប់នេះ។

**មាត្រា៥៣ .-**

ការគ្រោងចំណូល ត្រូវឈរលើមូលដ្ឋាននៃប្រភពធនធានថវិការបស់រដ្ឋដែលបានមកពីចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធ និងចំណូលផ្សេងៗ ដោយៈ

១-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវគ្រោងដោយផ្ទាល់នូវចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធ និងចំណូលផ្សេងៗ ដែលជាកម្មវត្ថុនៃការប្រមូលនៅក្រោមសមត្ថកិច្ចរបស់ខ្លួន។

២-រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ប្រធានគ្រប់អង្គភាពសាធារណៈប្រហាក់ប្រហែល និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ ដែលមានចំណែកក្នុងការគ្រប់គ្រងចំណូលក្រោមសមត្ថកិច្ចរបស់ខ្លួនត្រូវផ្ញើមករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនូវបញ្ជីរាយគ្រប់មុខចំណូល និងបញ្ជីប៉ាន់ស្មានចំណូលទាំងអស់ ដើម្បីកត់ត្រាក្នុងគម្រោងចំណូលនៃថវិកាឱ្យបានពេញលេញនិងត្រឹមត្រូវ។ ចំណូលទាំងនេះជាចំណែកមិនអាចបំបែកបាននៃចំណូលសរុបនៃថវិការដ្ឋ។

**មាត្រា៥៤ .-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវគ្រោងធនធានហិរញ្ញប្បទាន ដោយឈរលើមូលដ្ឋាននៃប្រភពបានមកពីៈ

១-ការបោះផ្សាយលក់មូលបត្ររដ្ឋ។

២-ការខ្ចីប្រាក់ពីស្ថាប័នហិរញ្ញវត្ថុនិងដៃគូអភិវឌ្ឍ។

៣-ប្រាក់បញ្ញើរបស់រាជរដ្ឋាភិបាល។

៤-ហិរញ្ញប្បទានពីប្រភពផ្សេងៗទៀត ស្របតាមបទប្បញ្ញត្តិជាធរមាន។

**មាត្រា៥៥ .-**

ការគ្រោងចំណាយចរន្តនិងចំណាយវិនិយោគ ត្រូវរៀបចំឡើងដោយរដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមការអនុវត្តកម្មវិធីនិងសកម្មភាពការងារទាំងមូល។



តេលេក្រាម ឯកសារមន្ត្រីសាធារណៈ - https://t.me/oa_channel

**មាត្រា៥៦ .-**

ការគ្រោងតម្រូវការថវិកា ត្រូវរៀបចំឡើងដោយហ្មត់ចត់និងច្បាស់លាស់ដោយផ្អែកលើគោលការណ៍ច្បាប់ គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលនយោបាយនិងយុទ្ធសាស្ត្រតាមវិស័យ ព្រមទាំងគោលបំណងគោលនយោបាយ កម្មវិធី និងលទ្ធផលរំពឹងទុក របស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែលពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបង្កើតនិយាមនិងឯកតារង្វាស់សម្រាប់រាល់សកម្មភាពការងារ ដែលមានលក្ខណៈផ្សេងៗគ្នា ព្រមទាំងសម្រាប់ទ្រព្យនិងសេវា ដោយសហការជាមួយនឹងក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែលពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា៥៧ .-**

ការគ្រោងចំណាយវិនិយោគត្រូវរៀបចំផ្អែកលើគម្រោងឬកម្មវិធីវិនិយោគដោយឡែកៗ ដែលមានការយល់ព្រមជាមុន ស្របតាមបទប្បញ្ញត្តិពាក់ព័ន្ធនឹងការគ្រប់គ្រងវិនិយោគសាធារណៈ និងដែលត្រូវបានរៀបចំឡើងសំដៅសម្រេចឱ្យបាននូវគោលបំណង ដែលបានកំណត់ក្នុងរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាល។ គម្រោងឬកម្មវិធីវិនិយោគទាំងអស់ គឺជាមូលដ្ឋានសម្រាប់វាយតម្លៃចំណាយវិនិយោគសរុបរបស់គម្រោងឬកម្មវិធី និងសម្រាប់កំណត់រយៈពេលនៃឥណទានភ្ជាប់សន្យានិងឥណទានទូទាត់ សម្រាប់ដំណាក់កាលនីមួយៗក្នុងឆ្នាំ។

**មាត្រា៥៨ .-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានសិទ្ធិគ្រោងចំណូលនិងចំណាយរបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលមិនបានលើកគម្រោងចំណូល និងចំណាយរបស់ខ្លួនតាមកាលកំណត់ ដោយផ្អែកលើលទ្ធផលនៃឆ្នាំកំពុងអនុវត្តដើម្បីធានាការគោរពតាមប្រតិទិននៃការរៀបចំ និងការអនុម័តសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំដូចមានចែងក្នុងមាត្រា៥១នៃច្បាប់នេះ។

**មាត្រា៥៩ .-**

សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ចែកចេញជាពីរផ្នែក។

ផ្នែកទី១ : បទប្បញ្ញត្តិនៃសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ រួមមាន៖

១-អនុញ្ញាតឱ្យប្រមូលគ្រប់ធនធានថវិការដ្ឋ និងកំណត់ធនធានទាំងនោះ ជាទឹកប្រាក់សរុប។

២-ចែងអំពីបទប្បញ្ញត្តិដែលពាក់ព័ន្ធដល់ធនធានថវិការដ្ឋ ដែលរួមមាន ចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធ និងចំណូលផ្សេងៗ។

៣-កំណត់នូវបន្ទុកថវិកា ជាឥណទានខ្ពស់បំផុតដែលត្រូវបានអនុញ្ញាតជាគុណប្រយោជន៍ដល់ថវិការដ្ឋ។

៤-ចែងអំពីបទប្បញ្ញត្តិដទៃទៀតពាក់ព័ន្ធនឹងបន្ទុកថវិការដ្ឋ រួមបញ្ចូលនូវពិតាននៃការឱ្យប្រាក់គេខ្ចី។

៥-កំណត់តុល្យភាពថវិកា/ សមតុល្យធនធាននិងបន្ទុកថវិកា។

៦-កំណត់ពិតានធនធានហិរញ្ញប្បទាន។

៧-ចែងអំពីបទប្បញ្ញត្តិពាក់ព័ន្ធនឹងធនធាននិងបន្ទុកហិរញ្ញប្បទាន រួមបញ្ចូលនូវពិតាននៃការខ្ចីប្រាក់ពីគេនិងការធានារបស់រដ្ឋ។

៨-ចែងអំពីបទប្បញ្ញត្តិពាក់ព័ន្ធនឹងមូលនិធិបម្រុងហិរញ្ញវត្ថុរបស់រដ្ឋ។

៩-ចែងអំពីបទប្បញ្ញត្តិហិរញ្ញវត្ថុផ្សេងៗទៀត។

ផ្នែកទី២ : តារាងឧបសម្ព័ន្ធនៃសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ រួមមាន៖

១-តារាងចំណូលថវិកាថ្នាក់ជាតិ ចែកជាប្រភេទ ជំពូក គណនី អនុគណនី និងតាមក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល។

២-តារាងចំណូលថវិការដ្ឋបាលរាជធានី ខេត្ត ចែកជាប្រភេទ ជំពូក គណនី អនុគណនី និងតាមរាជធានី ខេត្ត។

៣-តារាងចំណាយ បែងចែកទៅតាមក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល តាមប្រភេទចំណាយ។

៤-តារាងចំណាយតាមកម្មវិធី។

៥-តារាងចំណាយវិនិយោគ បែងចែកទៅតាមប្រភេទចំណាយដល់ក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល ដែលចែកចេញជាឥណទានភ្ជាប់សន្យានិងឥណទានទូទាត់។

៦-តារាងពិតានចំនួនបុគ្គលិកតាមក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

៧-តារាងចំណាយឧបត្ថម្ភធនទៅគ្រឹះស្ថានសាធារណៈរដ្ឋបាល។

៨-តារាងចំណូល ចំណាយថវិកាឧបសម្ព័ន្ធ និងគណនីពិសេសរតនាគារ(ថ្នាក់ជាតិ)។

៩-តារាងចំណាយថវិការដ្ឋបាលរាជធានី ខេត្ត(តាមប្រភេទចំណាយ តាមកម្មវិធី និងតាមរាជធានី ខេត្ត)។

១០-តារាងតុល្យភាពហិរញ្ញវត្ថុឆ្លុះបញ្ចាំងពីកិច្ចប្រតិបត្តិការថវិកាដែលជាសមតុល្យធនធាននិងបន្ទុកថវិកាព្រមទាំងឆ្លុះបញ្ចាំងពីតម្រូវការហិរញ្ញប្បទាននិងប្រភពហិរញ្ញប្បទាន។

**មាត្រា៦០ .-**

សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលត្រូវដាក់ជូនរដ្ឋសភានិងព្រឹទ្ធសភា ត្រូវភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម៖

១-សេចក្តីថ្លែងហេតុនៃសេចក្តីព្រាងច្បាប់នេះ។

២-ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម និងក្របខ័ណ្ឌថវិការយៈពេលមធ្យម ឬបច្ចុប្បន្នកម្មនៃឯកសារនេះ។

៣-ឧបសម្ព័ន្ធស្តីពីគម្រោងសមិទ្ធកម្មប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលរាជធានី ខេត្ត។

ក្រៅពីឯកសារខាងលើនេះ រាជរដ្ឋាភិបាល អាចផ្តល់ឯកសារពាក់ព័ន្ធផ្សេងទៀត ដើម្បីភ្ជាប់ទៅនឹងសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ សម្រាប់ជាព័ត៌មានបន្ថែម ជូនរដ្ឋសភានិងព្រឹទ្ធសភា។

**មាត្រា៦១ .-**

ក្នុងករណីសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ មិនត្រូវបានអនុម័តមុនថ្ងៃទី១ ខែមករា នៃឆ្នាំការិយបរិច្ឆេទ នោះចំណាត់ការដូចខាងក្រោម ត្រូវបានបន្តដោយស្របច្បាប់៖

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

តេលេក្រាម ឯកសារមន្ត្រីសាធារណៈ - https://t.me/oa_channel

១-ចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធ និងចំណូលផ្សេងៗ ត្រូវបានអនុញ្ញាតនិងបន្តឱ្យប្រមូល ក្នុងលក្ខខណ្ឌនិងតាមបទប្បញ្ញត្តិដែលបានកំណត់ក្នុងច្បាប់ហិរញ្ញវត្ថុពីមុន និងក្នុងក្របខ័ណ្ឌច្បាប់ ព្រមទាំងលិខិតបទដ្ឋានដែលមានជាធរមាន។

២-ចំណាយចរន្តថវិការដ្ឋ តាមក្របខ័ណ្ឌនៃឥណទានថវិកាឆ្នាំមុន ដោយគិតតាមវិធីមួយភាគដប់ពីរជាបណ្ដោះអាសន្នក្នុងខែនីមួយៗរហូតដល់ថវិកាថ្មីត្រូវបានអនុម័ត។

៣-ចំណាយវិនិយោគ ក្នុងកម្រិតឥណទានទូទាត់ដែលនៅទំនេរនៃក្របខ័ណ្ឌឥណទានថវិកាឆ្នាំមុន ហើយអាចលើសពីនេះក្នុងករណីចាំបាច់ ដោយមិនឱ្យការទូទាត់នោះលើសពីកម្រិតឥណទានភ្ជាប់សន្យា ដែលបានអនុម័តក្នុងថវិកាឆ្នាំមុន។

៤-ចំណាយបដិភាគសម្រាប់អនុវត្តគម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស និងបន្ទុកបំណុលសាធារណៈ រួមមានការរំលស់ប្រាក់ដើម ការប្រាក់ និងបន្ទុកពាក់ព័ន្ធផ្សេងៗស្របតាមកិច្ចព្រមព្រៀងជាធរមាន។

៥-ចំណាយទាំងឡាយដែលជាកាតព្វកិច្ចពាក់ព័ន្ធនឹងសមាជិកភាពរបស់កម្ពុជាក្នុងស្ថាប័នអន្តរជាតិនិងអន្តររដ្ឋាភិបាល។

## ផ្នែកទី៣
## សិទ្ធិអំណាចនិងការទទួលខុសត្រូវ

**មាត្រា៦២ .-**

ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវអនុម័តក្នុងលក្ខខណ្ឌដូចគ្នានឹងច្បាប់ដទៃទៀតដែរ លើកលែងតែករណីដូចខាងក្រោម៖

១-ធនធាន បន្ទុក និងតុល្យភាពថវិការដ្ឋ ដែលត្រូវអនុម័តសរុបជាកញ្ចប់ រួមបញ្ចូលនូវ៖

- ធនធាននិងបន្ទុកថវិកាថ្នាក់ជាតិ
- ធនធាននិងបន្ទុកថវិការដ្ឋបាលថ្នាក់ក្រោមជាតិ
- ធនធាន បន្ទុក និងតុល្យភាព/សមតុល្យថវិការដ្ឋ
- បទប្បញ្ញត្តិស្ដីពីធនធាននិងបន្ទុកហិរញ្ញប្បទាន។

២-បញ្ជីសរុបនៃថវិកាឧបសម្ព័ន្ធ និងគណនីពិសេសរតនាគារ ដែលត្រូវអនុម័តជាកញ្ចប់។

៣-បទប្បញ្ញត្តិផ្សេងទៀត ដែលត្រូវអនុម័តជាជំពូក។

៤-សេចក្ដីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំទាំងមូលដែលជាកម្មវត្ថុនៃការអនុម័តចុងក្រោយ។

**មាត្រា៦៣ .-**

ការកែប្រែបទប្បញ្ញត្តិណាមួយនៃសេចក្ដីព្រាងច្បាប់ហិរញ្ញវត្ថុ មិនអាចប្រព្រឹត្តទៅបានទេ ប្រសិនបើការកែប្រែនោះសំដៅបន្ថយធនធាន ឬបង្កើត ឬបន្ថែមបន្ទុកថវិការដ្ឋដែលធ្វើឱ្យប៉ះពាល់ជាសំខាន់ដល់តុល្យភាពនៃថវិកាដែលបានស្នើឡើង លើកលែងតែក្នុងករណីដូចខាងក្រោម៖

ក-ការស្នើចំណាយថ្មីដែលត្រូវបានធ្វើឡើងដោយលុបឬបន្ថយចំណាយណាមួយផ្សេងទៀត ដើម្បីរក្សាតុល្យភាពថវិកា

- ការស្នើចំណាយថ្មីដែលត្រូវបានធ្វើឡើងដោយមានភ្ជាប់ជាមួយនូវការស្នើសន្សំសំចៃលើប្រភេទចំណាយណាមួយដែលបានស្នើឡើងរួចហើយដើម្បីរក្សាតុល្យភាពថវិកា
- ការស្នើចំណាយថ្មីដែលត្រូវបានធ្វើឡើងដោយមានភ្ជាប់ជាមួយនូវការស្នើបង្កើតមុខចំណូលថ្មី ឬបង្កើនចំណូលដើម្បីរក្សាតុល្យភាពថវិកា។

ការកែប្រែបទប្បញ្ញត្តិណាមួយនៃសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ ត្រូវមានការវាយតម្លៃលើទំហំនៃផលប៉ះពាល់ក្នុងឆ្នាំអនុវត្ត និងក្នុងករណីចាំបាច់ក្នុងឆ្នាំបន្តបន្ទាប់។

ការកែប្រែបទប្បញ្ញត្តិណាមួយនៃសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ ត្រូវមានមូលហេតុនិងយុត្តិកម្មត្រឹមត្រូវ។

ការស្នើកែប្រែបទប្បញ្ញត្តិណាមួយនៃសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ ដែលផ្ទុយនឹងខ្លឹមសារនៃមាត្រានេះ មិនត្រូវយកមកពិនិត្យនិងអនុម័តនោះទេ។

**មាត្រា៦៤ .-**

ការបែងចែកឥណទានថវិកាជូនក្រសួង ស្ថាប័ន កម្រិតជំពូក និងកម្រិតកម្មវិធីនៃចំណាត់ថ្នាក់មាតិកាថវិកា ត្រូវអនុវត្តតាមមាត្រា៣៨នៃច្បាប់នេះ។ ការបែងចែកនេះមិនអាចនាំឱ្យមានការកែប្រែឥណទានថវិកាដែលត្រូវបានកំណត់ដោយច្បាប់ឡើយ។

## ជំពូកទី៤

## ការអនុវត្តថវិកា

### ផ្នែកទី១

### ក្របខ័ណ្ឌនៃការអនុវត្តថវិកា

**មាត្រា៦៥ .-**

ការផ្ទេរឥណទានថវិកាពីមួយទៅមួយរវាងក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលរាជធានី ខេត្ត ត្រូវកំណត់ដោយច្បាប់ហិរញ្ញវត្ថុ។

ក្នុងករណីមានភាពចាំបាច់នៃការពង្រឹងរចនាសម្ព័ន្ធស្ថាប័នរបស់រាជរដ្ឋាភិបាល ការផ្ទេរឥណទានថវិកា ពីមួយទៅមួយរវាងក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល អាចប្រព្រឹត្តទៅបានដោយអនុក្រឹត្យ ក្នុងលក្ខខណ្ឌដែលការផ្ទេរឥណទានថវិកានេះ មិនមានការកែប្រែមុខចំណាយនិងការបែងចែកឥណទានថវិកាតាមជំពូកនៃចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា និងមានគោលបំណងនៃសកម្មភាពដូចគ្នា។

ក្នុងករណីមានភាពចាំបាច់នៃការផ្ទេរមុខងារពីរដ្ឋបាលថ្នាក់ជាតិ ទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ការផ្ទេរឥណទានថវិកា ពីសាមីក្រសួង ស្ថាប័ន ឬអង្គភាពសាធារណៈប្រហាក់ប្រហែល ទៅរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានការពាក់ព័ន្ធ អាចប្រព្រឹត្តទៅបានដោយអនុក្រឹត្យ ក្នុងលក្ខខណ្ឌដែលការផ្ទេរឥណទានថវិកានេះមិនមានការកែប្រែមុខចំណាយនិងការបែងចែកឥណទានថវិកាតាមជំពូកនៃចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា និងមានគោលបំណងនៃសកម្មភាពដូចគ្នា។

ក្នុងករណីមានភាពចាំបាច់នៃការពង្រឹងរចនាសម្ព័ន្ធស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ ការផ្ទេរឥណទានថវិកាពីមួយទៅមួយរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ អាចប្រព្រឹត្តទៅបានដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



គេហទំព័រ ឯកសារផ្លូវការ - https://t.me/oa_channel

ក្នុងលក្ខខណ្ឌដែលការផ្ទេរឥណទានថវិកានេះ មិនមានការកែប្រែមុខចំណាយនិងការបែងចែកឥណទានថវិកាតាមជំពូកនៃចំណាត់ថ្នាក់សេដ្ឋកិច្ចនៃបាតិកាថវិកា និងមានគោលបំណងនៃសកម្មភាពដូចគ្នា។

**មាត្រា៦៦ .-**

ការបង្វែរឥណទានថវិកាពីជំពូកមួយទៅជំពូកមួយនៅផ្ទៃក្នុងថវិការបស់ក្រសួង ស្ថាប័ន ឬអង្គភាពសាធារណៈប្រហាក់ប្រហែល ត្រូវកំណត់ដោយអនុក្រឹត្យ។

ការបង្វែរឥណទានថវិកាពីកម្មវិធីមួយទៅកម្មវិធីមួយនៅផ្ទៃក្នុងថវិការបស់ក្រសួង ស្ថាប័ន ឬអង្គភាពសាធារណៈប្រហាក់ប្រហែល ត្រូវបានអនុញ្ញាតក្នុងកម្រិតយ៉ាងច្រើនបំផុត៥(ប្រាំ)ភាគរយនៃឥណទានកម្មវិធីនីមួយៗ។ ការបង្វែរឥណទានថវិកានេះ ត្រូវកំណត់ដោយអនុក្រឹត្យ។

នាយករដ្ឋមន្ត្រី អាចផ្ទេរសិទ្ធិសម្រេចក្នុងកម្រិតណាមួយជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំពោះការបង្វែរឥណទានថវិកាដែលមានចែងក្នុងកថាខណ្ឌទាំងពីរខាងលើ។ ក្នុងករណីដែលមានការផ្ទេរសិទ្ធិសម្រេចនេះ ការបង្វែរឥណទានថវិកា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ការបង្វែរឥណទានថវិកាពីជំពូកមួយទៅជំពូកមួយនៅផ្ទៃក្នុងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចធ្វើប្រតិភូកម្មជូនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ នូវសិទ្ធិសម្រេចក្នុងការធ្វើនិយ័តកម្មឥណទានថវិការបស់ខ្លួន ដើម្បីដោះស្រាយតម្រូវការក្នុងករណីចាំបាច់។

ការបង្វែរឥណទានថវិកាពីកម្មវិធីមួយទៅកម្មវិធីមួយនៅផ្ទៃក្នុងថវិការដ្ឋបាលរាជធានី ខេត្ត ត្រូវបានអនុញ្ញាតក្នុងកម្រិតយ៉ាងច្រើនបំផុត៥(ប្រាំ)ភាគរយនៃឥណទានកម្មវិធីនីមួយៗ។ ការបង្វែរឥណទានថវិកានេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

វិធាននិងនីតិវិធីនៃការបង្វែរឥណទានថវិកាផ្ទៃក្នុងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៦៧ .-**

ការបង្វែរឥណទានថវិកាពីគណនីមួយទៅគណនីមួយក្នុងជំពូកតែមួយ និងពីអនុកម្មវិធីមួយទៅអនុកម្មវិធីមួយក្នុងកម្មវិធីតែមួយ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចចេញប្រកាសផ្ទេរសិទ្ធិអំណាចនៃការបង្វែរឥណទានថវិកានេះទៅក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលរាជធានី ខេត្ត។

ការបង្វែរឥណទានថវិកាពីអនុគណនីមួយទៅអនុគណនីមួយក្នុងគណនីតែមួយ និងពីចង្កោមសកម្មភាពមួយទៅចង្កោមសកម្មភាពមួយក្នុងអនុកម្មវិធីតែមួយ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួង ឬដោយសេចក្តីសម្រេចរបស់ប្រធានស្ថាប័ន ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត លើកលែងតែមុខចំណាយមួយចំនួនដែលមានហានិភ័យក្នុងការគ្រប់គ្រងថវិកា។ មុខចំណាយដែលត្រូវបានលើកលែងនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលត្រូវធ្វើបច្ចុប្បន្នកម្មជាទៀងទាត់ស្របតាមតម្រូវការជាក់ស្តែង។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវសិក្សា ពិនិត្យ និងកែសម្រួលបន្ថែមជាបន្តបន្ទាប់នូវសិទ្ធិក្នុងការបង្វែរឥណទានថវិកានៅផ្ទៃក្នុងជំពូក និងផ្ទៃក្នុងកម្មវិធី ជូនដល់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលរាជធានី ខេត្ត ស្របតាមគោលការណ៍នៃការអនុវត្តថវិកាសមិទ្ធកម្ម។

វិធាននិងនីតិវិធីនៃការបង្វែរឥណទានថវិកានៅផ្ទៃក្នុងជំពូកនិងផ្ទៃក្នុងកម្មវិធី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៦៨ .-**

ការបែងចែកឥណទានថវិកាដែលកត់ត្រានៅក្នុងចំណាយមិនទាន់បែងចែកមានមុខសញ្ញា និងចំណាយមិនបានគ្រោងទុក ក្រោមរូបភាពនៃឥណទានថវិកាបន្ថែមជាគុណប្រយោជន៍ដល់កម្មវិធី និងជំពូកផ្សេងៗរបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយអនុក្រឹត្យតាមការស្នើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៦៩ .-**

នៅក្នុងការិយបរិច្ឆេទនៃឆ្នាំថវិកា ឥណទានថវិកាសម្រាប់មុខសញ្ញាដែលលែងមានតម្រូវការប្រើប្រាស់អាចត្រូវបានលុបដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៧០ .-**

នៅពេលដែលការវិវត្តនៃចំណូល និងចំណាយ ស្តែងចេញឱ្យឃើញនូវការបាត់តុល្យភាពថវិកា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចចេញជាប្រកាសដើម្បីបង្កកមួយចំណែកឬទាំងស្រុងនៃប្រភេទឥណទានថវិកាមួយចំនួនដែលបានអនុម័តនៅក្នុងច្បាប់ហិរញ្ញវត្ថុ។ ក្នុងករណីដែលការបាត់តុល្យភាពនេះមានលក្ខណៈធ្ងន់ធ្ងរ រាជរដ្ឋាភិបាលអាចចេញអនុក្រឹត្យតាមការស្នើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយលុបមួយចំណែកឬទាំងស្រុងនៃប្រភេទឥណទានថវិកាមួយចំនួនដែលបានអនុម័តក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។ ការលុបឥណទាននេះ ជាកម្មវត្ថុនៃការអនុម័តដោយច្បាប់ទូទាត់ថវិកា។

**មាត្រា៧១ .-**

ក្នុងករណីមានតម្រូវការចាំបាច់ដើម្បីអន្តរាគមន៍ ឬដោះស្រាយបញ្ហាប្រឈមដែលបង្កដោយគ្រោះអាសន្ននិងគ្រោះមហន្តរាយ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ផលប្រយោជន៍ជាតិ ផ្អែកលើរបាយការណ៍របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នាយករដ្ឋមន្ត្រីអាចចេញអនុក្រឹត្យៈ

- ផ្ទេរឥណទានថវិកាពីមួយទៅមួយរវាងក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងផ្ទេរឥណទាននៅផ្ទៃក្នុងថវិការបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយអនុញ្ញាតឱ្យកែប្រែមុខចំណាយ និងបែងចែកឥណទានថវិកាដែលផ្ទេរនេះឡើងវិញ
- បន្ថែមឥណទានថវិកាដើម្បីប្រើប្រាស់ តាមករណីចាំបាច់នីមួយៗ។

ការផ្ទេរនិងការបន្ថែមឥណទានថវិកានេះ ជាកម្មវត្ថុនៃការអនុម័តដោយច្បាប់ហិរញ្ញវត្ថុកែតម្រូវ នៅពេលដែលស្ថានភាពពិសេសទាំងនេះត្រូវបានចប់សព្វគ្រប់។



គេហទំព័រ ឯកសារផ្លូវការ - https://t.me/oa_channel

ដោយបដិប្បញ្ញត្តិទៅនឹងកថាខណ្ឌខាងលើនេះ ប្រសិនបើច្បាប់ហិរញ្ញវត្ថុកែតម្រូវនេះមិនអាចធ្វើទៅកើតក្នុងការិយបរិច្ឆេទនៃឆ្នាំថវិកាដែលកើតមានព្រឹត្តិការណ៍ ការផ្ទេរនិងការបន្ថែមឥណទានថវិកាទាំងនេះជាកម្មវត្ថុនៃនិយ័តភាវូបនីយកម្មក្នុងច្បាប់ទូទាត់ថវិកានៃឆ្នាំអនុវត្ត។

**មាត្រា៧២ .-**

ការកែប្រែផ្សេងៗលើច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ អាចធ្វើទៅបាននៅក្នុងអំឡុងពេលនៃឆ្នាំថវិកាតាមរយៈច្បាប់ហិរញ្ញវត្ថុកែតម្រូវដែលត្រូវដាក់សុំការអនុម័តយល់ព្រមពីរដ្ឋសភានិងព្រឹទ្ធសភា ដូចការអនុម័តច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំដែរ។

**មាត្រា៧៣ .-**

ច្បាប់ហិរញ្ញវត្ថុកែតម្រូវ ត្រូវរៀបចំដោយផ្នែកឬទាំងស្រុងដែលមានទម្រង់ដូចគ្នានឹងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។ ច្បាប់ហិរញ្ញវត្ថុកែតម្រូវ មានឧបសម្ព័ន្ធដូចខាងក្រោម៖

១-របាយការណ៍បង្ហាញពីមូលហេតុនិងគោលដៅនៃការកែប្រែឥណទានថវិកា ដោយឆ្លុះបញ្ចាំងពីស្ថានភាពនៃការអនុវត្តនិងតុល្យភាពនៃថវិកា។

២-ឧបសម្ព័ន្ធពន្យល់លម្អិតអំពីតម្រូវការឥណទានថវិកាដែលបានស្នើសុំការកែប្រែ។

៣-តារាងសង្ខេបអំពីចលនាឥណទានថវិកាដែលនាំឱ្យមានការកែប្រែក្នុងឆ្នាំអនុវត្ត។

## ផ្នែកទី២
## ដំណើរការនៃការអនុវត្តថវិកា

**មាត្រា៧៤ .-**

ការអនុវត្តកិច្ចប្រតិបត្តិការហិរញ្ញវត្ថុនិងគណនេយ្យរបស់រដ្ឋ ជាភារកិច្ចរបស់អាណាប័កនិងគណនេយ្យករសាធារណៈ។

មុខងារជាអាណាប័កនិងមុខងារជាគណនេយ្យករសាធារណៈ មានវិសមិតភាពនឹងគ្នា។

រដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័ន ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក និងមេឃុំ គឺជាអាណាប័កដើមខ្សែនៃថវិការបស់ខ្លួន។ មុខងារជាអាណាប័ករបស់អភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀត ត្រូវអនុវត្តស្របតាមបទប្បញ្ញត្តិជាធរមាន។

អាណាប័កដើមខ្សែ ជាអ្នកបញ្ជាចំណូលនិងចំណាយថវិការដ្ឋ ចំពោះឥណទានថវិកា ដែលត្រូវបានវិភាជជូនសាមីក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

អាណាប័កដើមខ្សែ ត្រូវប្រគល់សិទ្ធិជូនប្រធានអង្គភាពថវិកាក្រោមឱវាទ ជាអាណាប័កផ្ទេរសិទ្ធិ សម្រាប់អនុវត្តកិច្ចប្រតិបត្តិការថវិកាក្នុងវង្វង់ឥណទានថវិកាដែលត្រូវបានវិភាជជូន ដើម្បីសម្រេចសមិទ្ធកម្មតាមការគ្រោងទុក។ សិទ្ធិអំណាចនិងការទទួលខុសត្រូវរបស់អង្គភាពថវិកា ត្រូវកំណត់ដោយអនុក្រឹត្យ តាមការស្នើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

អាណាប័កដើមខ្សែឬអាណាប័កផ្ទេរសិទ្ធិ អាចចាត់តាំងថ្នាក់ដឹកនាំក្រោមឱវាទ ជាអាណាប័កជំនួសដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់អាណាប័ក ព្រមទាំងការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិនិង អាណាប័កជំនួស ត្រូវកំណត់ដោយអនុក្រឹត្យតាមការស្នើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៧៥ .-**

ការអនុវត្តថវិការដ្ឋ ជាកម្មវត្ថុនៃការត្រួតពិនិត្យថវិកាដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបង្កើតអង្គភាពត្រួតពិនិត្យថវិកា ឱ្យនៅអមក្រសួង ស្ថាប័ន អង្គភាពសាធារណៈ ប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងធ្វើប្រតិភូកម្មមុខងារជូនអង្គភាពត្រួតពិនិត្យថវិកានេះ ដើម្បីអនុវត្ត ការត្រួតពិនិត្យថវិកា។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចផ្ទេរសិទ្ធិជូនអង្គភាពណាមួយដែលនៅជៀក ឬស្ថិតនៅកម្រិត អនុវត្តថវិកា ឱ្យអនុវត្តការត្រួតពិនិត្យថវិកាខាងលើនេះ។ ការធ្វើប្រតិភូកម្មមុខងារនិងការផ្ទេរសិទ្ធិត្រួតពិនិត្យថវិកា ខាងលើនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ការត្រួតពិនិត្យថវិកា អាចធ្វើឡើងតាមនីតិវិធីខ្លី សាមញ្ញ និងបត់បែនបាន អាស្រ័យលើមុខចំណាយ ឬអង្គភាព អនុវត្តថវិកា ដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

វិធាន និងនីតិវិធីអនុវត្តនិងត្រួតពិនិត្យថវិកា ព្រមទាំងមុខងារនិងភារកិច្ចរបស់អង្គភាពត្រួតពិនិត្យថវិកា ត្រូវ កំណត់ដោយអនុក្រឹត្យតាមការស្នើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៧៦ .-**

រាល់ចំណាយថវិការដ្ឋ សម្រាប់ការទិញ ការសាងសង់ ការជួសជុល ការជួលសេវា ត្រូវអនុលោមតាមវិធាននិង នីតិវិធី ដែលកំណត់ក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈជាធរមាន។

## ផ្នែកទី៣

## ការតាមដាននិងវាយតម្លៃការអនុវត្តថវិកា

**មាត្រា៧៧ .-**

ក្នុងក្របខ័ណ្ឌនៃថវិកាសមិទ្ធកម្ម ការតាមដាននិងវាយតម្លៃការអនុវត្តថវិកា ត្រូវធ្វើឡើងដោយផ្អែកលើឧបករណ៍ និងវិធីសាស្ត្រសម្រាប់វាស់វែងនិងវាយតម្លៃ។

ការតាមដាន ត្រូវពិនិត្យមើលគុណភាពនៃការរៀបចំកម្មវិធី ការអនុវត្តកម្មវិធីនិងសមិទ្ធកម្ម និងការប្រើប្រាស់ ធនធាន។ ដោយឡែក ការវាយតម្លៃ ត្រូវពិនិត្យលើសក្តិសិទ្ធភាពនិងសមិទ្ធកម្មដែលសម្រេចបានប្រចាំឆ្នាំ និងពហុឆ្នាំ នៃកម្មវិធីរបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

ស្ថិតក្រោមក្របខ័ណ្ឌគណនេយ្យភាព រដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័ន ប្រធានអង្គភាពសាធារណៈ ប្រហាក់ប្រហែល និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំរបាយការណ៍សមិទ្ធកម្ម ប្រចាំឆ្នាំ តាមគោលការណ៍និងវិធីសាស្ត្រដែលកំណត់ក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពិនិត្យដោយបញ្ជាក់អនុលោមភាព និងផ្តល់អនុសាសន៍លើរបាយការណ៍ សមិទ្ធកម្មរបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីប្រើប្រាស់ជាធាតុចូលសម្រាប់កែលម្អផែនការសមិទ្ធកម្មនាឆ្នាំបន្ទាប់។



តេលេក្រាម ឯកសារមន្ត្រីសាធារណៈ - https://t.me/oa_channel

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចផ្តួចផ្តើម និងដឹកនាំការវាយតម្លៃ តាមការចាំបាច់ និងតាមការជ្រើសរើស ដើម្បីវាស់វែងប្រសិទ្ធភាពនិងសក្តិសិទ្ធភាពនៃកម្មវិធី។

ក្របខ័ណ្ឌ វិធីសាស្ត្រ យន្តការ និងនីតិវិធីក្នុងការតាមដាននិងវាយតម្លៃ ក្នុងក្របខ័ណ្ឌថវិកាសមិទ្ធកម្ម ត្រូវកំណត់ដោយអនុក្រឹត្យ។

## ផ្នែកទី៤

## សិទ្ធិអំណាចនិងការទទួលខុសត្រូវ

**មាត្រា៧៨ .-**

ស្ថិតក្រោមលក្ខខណ្ឌ និងកម្រិតកំណត់នៃសិទ្ធិអំណាចដែលបានផ្តល់ក្នុងច្បាប់ហិរញ្ញវត្ថុ និងក្រោមអំណាចរបស់នាយករដ្ឋមន្ត្រី មានតែរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុម្នាក់គត់ ដែលមានសិទ្ធិក្នុងការខ្ចីប្រាក់ពីគេរួមបញ្ចូលនូវការបោះផ្សាយមូលបត្ររដ្ឋ ការទទួលហិរញ្ញប្បទានឥតសំណង ការវិនិយោគលើទ្រព្យសកម្មហិរញ្ញវត្ថុ ការធានានិងការសន្យាផ្ទេកហិរញ្ញវត្ថុនានា និងមានសិទ្ធិក្នុងការឱ្យប្រាក់គេខ្ចី ទាំងក្នុងនិងក្រៅប្រទេស។ ក្រៅពីនេះ គ្មានអ្នករាជការសាធារណៈ ឬពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោតណាមួយ មានសិទ្ធិក្នុងការខ្ចីប្រាក់ពីគេឬឱ្យប្រាក់គេខ្ចី ឬចេញជាលិខិតធានា ឬក៏ធ្វើទង្វើណាផ្សេងៗទៀត ដោយផ្ទាល់ឬដោយប្រយោល ដែលអាចនាំឱ្យកើតមាននូវបំណុលឬបន្ទុកហិរញ្ញវត្ថុផ្សេងទៀត ដោយផ្ទាល់ឬដោយប្រយោលដល់ព្រះរាជាណាចក្រកម្ពុជាបានទេ។

ចំពោះការខ្ចីប្រាក់ពីគេ និងការបង្កើតកាតព្វកិច្ចហិរញ្ញវត្ថុនានារបស់សហគ្រាសសាធារណៈ ត្រូវគោរពតាមលក្ខខណ្ឌ ដែលកំណត់ក្នុងបទប្បញ្ញត្តិច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងសហគ្រាសសាធារណៈ និងតាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ស្ថិតក្រោមកម្រិតកំណត់នៃច្បាប់ហិរញ្ញវត្ថុនិងក្រោមអំណាចរបស់នាយករដ្ឋមន្ត្រី មានតែរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុម្នាក់គត់ ដែលមានសិទ្ធិរៀបចំកម្មវិធីដោះស្រាយបំណុលដែលរដ្ឋជំពាក់គេឬបំណុលដែលគេជំពាក់រដ្ឋ។

**មាត្រា៧៩ .-**

រដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័ន និងប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល ព្រមទាំងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ មានកាតព្វកិច្ចទទួលខុសត្រូវចំពោះការអនុវត្តថវិកា និងលើការសម្រេចបាននូវសមិទ្ធកម្ម ដែលបានគ្រោងក្នុងដែនសមត្ថកិច្ចរៀងៗខ្លួន ក្នុងក្របខ័ណ្ឌដែលច្បាប់បានកំណត់។

**មាត្រា៨០ .-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភារកិច្ចគ្រប់គ្រងលទ្ធកម្មសាធារណៈនិងចេញលិខិតបទដ្ឋានគតិយុត្ត ដើម្បីណែនាំការអនុវត្តកិច្ចលទ្ធកម្មសាធារណៈដល់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ សហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀតពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈជាធរមាន។

តេលេក្រាម មន្ត្រីសាធារណៈ - https://t.me/oa_channel

**មាត្រា៨១ .-**

រដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័ន ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ ប្រធានសហគ្រាសសាធារណៈ និងនាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវធានាអនុលោមភាពពេញលេញ ការទទួលខុសត្រូវ តម្លាភាព និងគណនេយ្យភាព ក្នុងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈជាធរមាន។

**មាត្រា៨២ .-**

ប្រធានកម្មវិធី មានភារកិច្ចទទួលខុសត្រូវចំពោះមុខរដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័ន ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ លើការរៀបចំថវិកា ការសម្របសម្រួល ការតាមដាន និងការជំរុញកិច្ចប្រតិបត្តិការនានាក្នុងកម្រិតកម្មវិធី រួមទាំងការអនុវត្តថវិកានិងសម្រេចបាននូវសមិទ្ធកម្មតាមការគ្រោងទុក។

ប្រធានអង្គភាពថវិកា មានភារកិច្ចទទួលខុសត្រូវលើកិច្ចប្រតិបត្តិការនានាក្នុងក្របខ័ណ្ឌសិទ្ធិអំណាចនិងការទទួលខុសត្រូវរបស់ខ្លួន រួមទាំង ការរៀបចំ ការអនុវត្តថវិកា និងសមិទ្ធកម្មដែលបានគ្រោងចំពោះមុខប្រធានកម្មវិធីនិងអាណាប័កដើមខ្សែ។

សិទ្ធិអំណាច ភារកិច្ច និងការទទួលខុសត្រូវរបស់ប្រធានកម្មវិធីនិងអង្គភាពថវិកាត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៨៣ .-**

ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុជាសេនាធិការ ទទួលបន្ទុកការងារបច្ចេកទេសហិរញ្ញវត្ថុ និងទទួលបន្ទុកសម្របសម្រួលនិងគាំទ្រដល់កិច្ចប្រតិបត្តិការនានានៃកម្មវិធីទាំងឡាយ រួមមានជាអាទិ៍ ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ការរៀបចំថវិកាប្រចាំឆ្នាំ ការអនុវត្តថវិកា ការត្រួតពិនិត្យ និងការតាមដាននិងវាយតម្លៃ ព្រមទាំងលទ្ធផលនៃការអនុវត្តថវិការបស់ខ្លួន រួមបញ្ចូលនូវរបាយការណ៍អនុវត្តថវិកានិងរបាយការណ៍សមិទ្ធកម្ម។

តួនាទី ភារកិច្ច សិទ្ធិអំណាច និងការទទួលខុសត្រូវ ព្រមទាំងគុណវុឌ្ឍិរបស់ប្រធានអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៥

## គណនេយ្យនិងការទូទាត់ថវិកា

### ផ្នែកទី១

### ក្របខ័ណ្ឌគណនេយ្យ

**មាត្រា៨៤ .-**

គោរពតាមគោលការណ៍គណនេយ្យភាព រដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័ន ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ ប្រធានសហគ្រាសសាធារណៈ និងនាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំ និងផ្តល់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នូវរបាយការណ៍ដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ខ្លួន រួមមាន របាយការណ៍ចំណូលនិងចំណាយថវិការដ្ឋ

របាយការណ៍សមិទ្ធកម្ម របាយការណ៍ស្តីពីការអនុវត្តគម្រោងដែលពាក់ព័ន្ធនឹងការខ្ចីប្រាក់ពីគេ ការឱ្យប្រាក់គេខ្ចី ការធានារបស់រដ្ឋ និងហិរញ្ញប្បទានឥតសំណង និងរបាយការណ៍ដែលពាក់ព័ន្ធនឹងចំណូលមានប្រភពមកពីការវិនិយោគលើទ្រព្យសកម្មហិរញ្ញវត្ថុ ព្រមទាំងព័ត៌មានផ្សេងៗទៀត តាមការស្នើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវកំណត់ប្រភេទ លក្ខខណ្ឌ កាលបរិច្ឆេទនៃការផ្តល់ និងគំរូនៃរបាយការណ៍ ដូចមានចែងក្នុងកថាខណ្ឌខាងលើ។

**មាត្រា៨៥ .-**

កិច្ចប្រតិបត្តិការហិរញ្ញវត្ថុនិងគណនេយ្យនៃថវិការដ្ឋ ត្រូវអនុវត្តដោយគណនេយ្យករសាធារណៈ។ ការធ្វើមជ្ឈការតួលេខ ត្រូវធ្វើឡើងដោយគណនេយ្យកររតនាគារ ដែលជាគណនេយ្យករសាធារណៈនៅរតនាគារជាតិ។

កិច្ចប្រតិបត្តិការហិរញ្ញវត្ថុនិងគណនេយ្យនៃថវិការដ្ឋត្រូវផ្ទៀងផ្ទាត់ភាពត្រឹមត្រូវ ស្របតាមវិធានគណនេយ្យសាធារណៈ និងការគ្រប់គ្រងសាច់ប្រាក់ដោយគណនេយ្យករសាធារណៈ។

គ្រប់ប្រតិបត្តិការហិរញ្ញវត្ថុនិងគណនេយ្យនៃថវិការដ្ឋ ត្រូវមានលិខិតយុត្តិការជាសំអាងនិងអនុវត្តជាទម្រង់អេឡិចត្រូនិក ឬឌីជីថលក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ វិធាននិងនីតិវិធីនៃការកំណត់លិខិតយុត្តិការ និងទម្រង់អេឡិចត្រូនិក និងឌីជីថលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៨៦ .-**

គណនេយ្យសាធារណៈ គឺជាប្រព័ន្ធនៃការកត់ត្រា ការចាត់ថ្នាក់ ការវាស់វែង ការផ្តុំបញ្ចូលគ្នា និងការបង្ហាញព័ត៌មានថវិកានិងហិរញ្ញវត្ថុ ដែលអនុញ្ញាតឱ្យមានការត្រួតពិនិត្យលើទិន្នន័យនៃប្រតិបត្តិការថវិកា និងគណនេយ្យ និងបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍អនុវត្តថវិកា ព្រមទាំងការគណនានិងវិភាគលើចំណូលនិងថ្លៃដើមជាក់ស្តែងនៃសកម្មភាពឬសេវាកម្ម និងជាមូលដ្ឋានសម្រាប់ការវាយតម្លៃលើសមិទ្ធកម្ម។

ប្រភេទគណនេយ្យសាធារណៈ មានគណនេយ្យថវិកា គណនេយ្យទូទៅ និងគណនេយ្យវិភាគ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចកំណត់ប្រភេទគណនេយ្យសាធារណៈដទៃទៀត តាមតម្រូវការចាំបាច់ ក្នុងគោលបំណងធានាដល់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យមានប្រសិទ្ធភាពនិងសក្តិសិទ្ធភាព។

គណនេយ្យសាធារណៈត្រូវយកទៅអនុវត្តចំពោះថវិការដ្ឋ លើកលែងតែថវិការបស់សហគ្រាសសាធារណៈ។

ការកាន់បញ្ជីគណនេយ្យ និងការរៀបចំរបាយការណ៍នៃគណនេយ្យសាធារណៈត្រូវធ្វើជាភាសាខ្មែរ និងជាប្រាក់រៀល។

ការិយបរិច្ឆេទគណនេយ្យនីមួយៗត្រូវកំណត់រយៈពេលចំនួន១២(ដប់ពីរ)ខែ ដោយគិតចាប់ពីថ្ងៃទី១ ខែមករា រហូតដល់កាលបរិច្ឆេទបិទបញ្ជីគណនេយ្យនៅថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំដដែល។

**មាត្រា៨៧ .-**

គណនេយ្យថវិកា កត់ត្រា តាមដាន និងរាយការណ៍អំពីការប្រើប្រាស់ឥណទានថវិកា ទាំងចំណូលនិងចំណាយថវិការដ្ឋ ដែលមានកំណត់ដោយច្បាប់ហិរញ្ញវត្ថុ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

គណនេយ្យថវិកាត្រូវរៀបចំឡើងដោយឈរលើមូលដ្ឋានសាច់ប្រាក់។ ការកត់ត្រាចំណូល និងចំណាយថវិការដ្ឋត្រូវគោរពតាមគោលការណ៍ ដូចខាងក្រោម៖

- ត្រូវទទួលស្គាល់ជាចំណូលថវិកា នៅក្នុងឆ្នាំអនុវត្តថវិកា នៅពេលដែលចំណូលទាំងនោះត្រូវបានទទួលជាសាច់ប្រាក់រួចរាល់ ដោយគណនេយ្យករសាធារណៈ
- ត្រូវទទួលស្គាល់ជាចំណាយថវិកា នៅក្នុងឆ្នាំអនុវត្តថវិកា នៅពេលដែលចំណាយទាំងនោះត្រូវបានទូទាត់ជាសាច់ប្រាក់រួចរាល់ ដោយគណនេយ្យករសាធារណៈ។

សលាកបត្របង្វែរចំណូល និងអាណត្តិបើកប្រាក់ ក្នុងការិយបរិច្ឆេទនៃឆ្នាំអនុវត្តថវិកា អាចត្រូវបានបន្តទទួលយ៉ាងយូរត្រឹមថ្ងៃទី៣១ ខែមករា នៃឆ្នាំបន្ទាប់ ដោយត្រូវកត់ត្រាលេខនាបន្ថែមនៅត្រឹមថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំអនុវត្ត។

ក្នុងករណីដែលមានច្បាប់ហិរញ្ញវត្ថុកែតម្រូវ ត្រូវបានអនុម័តនៅក្នុងឆ្នាំអនុវត្តថវិកាឬមានអនុក្រឹត្យបន្ថែមឥណទានថវិកា ស្របតាមមាត្រា៧១នៃច្បាប់នេះ ចំណូលនិងចំណាយថវិកាដែលបានគ្រោងក្នុងច្បាប់ហិរញ្ញវត្ថុកែតម្រូវ ឬអនុក្រឹត្យនេះ អាចអនុវត្តបានក្នុងអំឡុងនៃរយៈពេលបំពេញបន្ថែម និងត្រូវចុះកិច្ចបញ្ជិកាគណនេយ្យនៅក្នុងការិយបរិច្ឆេទអនុវត្តថវិកាប្រចាំឆ្នាំ។ រយៈពេលបំពេញបន្ថែមនៃការអនុវត្តថវិកាសម្រាប់ករណីនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៨៨ .-**

ធនធាននិងបន្ទុកហិរញ្ញប្បទានរបស់រដ្ឋត្រូវធ្វើការកត់ត្រាទៅតាមប្លង់គណនេយ្យសាធារណៈ និងទៅតាមមុខសញ្ញាឬប្រភេទនៃប្រតិបត្តិការសាច់ប្រាក់នីមួយៗ។ ប្រតិបត្តិការចំណូលនិងចំណាយថវិកាដែលកើតចេញពីប្រតិបត្តិការសាច់ប្រាក់ ត្រូវកត់ត្រាទៅតាមមុខសញ្ញាចំណូលនិងចំណាយ ស្របតាមលក្ខខណ្ឌដែលមានកំណត់ក្នុងមាត្រា៨៧នៃច្បាប់នេះ។

**មាត្រា៨៩ .-**

គណនេយ្យទូទៅ កត់ត្រាគ្រប់ប្រតិបត្តិការហិរញ្ញវត្ថុនិងគណនេយ្យ និងរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលឆ្លុះបញ្ចាំងអំពីភាពពិតប្រាកដនិងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុនិងលទ្ធផលហិរញ្ញវត្ថុ។

គណនេយ្យទូទៅ ត្រូវរៀបចំឡើងដោយឈរលើមូលដ្ឋានបង្គរ និងត្រូវអនុវត្តតាមស្តង់ដាគណនេយ្យសាធារណៈរបស់កម្ពុជា។

កិច្ចប្រតិបត្តិការហិរញ្ញវត្ថុនិងគណនេយ្យនៃថវិការដ្ឋត្រូវបានទទួលស្គាល់ក្នុងបញ្ជីគណនេយ្យនៅក្នុងការិយបរិច្ឆេទដែលប្រតិបត្តិការទាំងនោះបានកើតឡើង ដោយមិនអាស្រ័យលើការទទួលបានសាច់ប្រាក់ឬការទូទាត់សាច់ប្រាក់។

គណនេយ្យទូទៅត្រូវធានាគុណភាពនៃគណនី ទិន្នន័យហិរញ្ញវត្ថុនិងគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ។

វិធាននិងនីតិវិធីនៃការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យសាធារណៈ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្របតាមយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL



https://t.me/oa_channel

**មាត្រា៩០ .-**

គណនេយ្យវិភាគ វាស់វែងនូវថ្លៃដើមក្នុងការផលិតផលិតផល ផ្តល់សេវាសាធារណៈ ឬកិច្ចអន្តរាគមន៍ផ្សេងទៀតរបស់រដ្ឋ ទៅតាមអង្គភាព មុខងារ វិស័យ កម្មវិធី ឬគម្រោង ដើម្បីជាមូលដ្ឋានបន្ថែមដល់ការសម្រេចចិត្តលើការគ្រប់គ្រងរបស់រដ្ឋបាលសាធារណៈ។

គណនេយ្យវិភាគ ត្រូវបានរៀបចំឡើងដោយឈរលើមូលដ្ឋានទិន្នន័យនៃគណនេយ្យថវិកានិងគណនេយ្យទូទៅ។

**មាត្រា៩១ .-**

បទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ ត្រូវកំណត់គ្រប់លក្ខខណ្ឌ ដែលធ្វើឱ្យកិច្ចប្រតិបត្តិការហិរញ្ញវត្ថុនិងគណនេយ្យ អាចកត់ត្រា វិភាគ និងគ្រប់គ្រងការអនុវត្តច្បាប់ហិរញ្ញវត្ថុ ប្រកបដោយគណនេយ្យភាព ប្រសិទ្ធភាព និងសក្តិសិទ្ធភាព។

បទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ ត្រូវកំណត់ដោយអនុក្រឹត្យ។

## ផ្នែកទី២
## ការទូទាត់ថវិកា

**មាត្រា៩២ .-**

ការទូទាត់ថវិកា គឺជាកម្មវត្ថុនៃច្បាប់ទូទាត់ថវិកា។

**មាត្រា៩៣ .-**

សេចក្តីព្រាងច្បាប់ទូទាត់ថវិកា ត្រូវរៀបចំដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយផ្អែកលើទិន្នន័យចំណូល ចំណាយ និងព័ត៌មានហិរញ្ញវត្ថុដទៃទៀតដែលរាយការណ៍ដោយគណនេយ្យករសាធារណៈ និងទៅតាមសមិទ្ធកម្មនៃការអនុវត្តថវិកាដែលរាយការណ៍ដោយអាណាប័កដើមខ្សែ។

សេចក្តីព្រាងច្បាប់ទូទាត់ថវិកា ចែកចេញជាពីរផ្នែក។

ផ្នែកទី១ : បទប្បញ្ញត្តិនៃសេចក្តីព្រាងច្បាប់ទូទាត់ថវិកា រួមមានៈ

១-ការបញ្ចប់នូវចំនួនទឹកប្រាក់ជាស្ថាពរនៃចំណូល ចំណាយ និងលទ្ធផលថវិកា ដែលបានអនុវត្តនៅក្នុងការិយបរិច្ឆេទនៃឆ្នាំថវិកា។

២-ការបញ្ចប់នូវចំនួនទឹកប្រាក់ជាស្ថាពរនៃធនធាននិងបន្ទុកហិរញ្ញប្បទាន ដែលធានាដល់តុល្យភាពហិរញ្ញវត្ថុនៃឆ្នាំអនុវត្តថវិកា និងបានបង្ហាញនៅក្នុងតារាងតុល្យភាពហិរញ្ញវត្ថុ។

៣-ការអនុម័តលើស្ថានភាពហិរញ្ញវត្ថុនិងលទ្ធផលនៃការិយបរិច្ឆេទ ដែលមានកំណត់ក្នុងមាត្រា៨៩នៃច្បាប់នេះស្តីពីគណនេយ្យទូទៅ ។

៤-ការទទួលស្គាល់នូវនិយ័តភាពឥណទានថវិការួមមាន ការផ្ទេរ ការបន្ថែមឥណទានថវិកា និងការលុបឥណទានថវិកា ក្នុងករណីដែលកើតមានឡើងក្នុងការិយបរិច្ឆេទនៃឆ្នាំថវិកា។

៥-ការទុកជាមោឃៈនូវឥណទានថវិកាដែលមិនបានប្រើប្រាស់ លើកលែងតែមានបដិប្បញ្ញត្តិដែលអនុញ្ញាតដោយច្បាប់នេះ។

៦-បទប្បញ្ញត្តិពាក់ព័ន្ធនឹងព័ត៌មានហិរញ្ញវត្ថុចាំបាច់ផ្សេងៗទៀត។

ផ្នែកទី២ : តារាងឧបសម្ព័ន្ធនៃសេចក្តីព្រាងច្បាប់ទូទាត់ថវិកា រួមមាន៖

១-តារាងតុល្យភាពហិរញ្ញវត្ថុ និងតារាងកិច្ចប្រតិបត្តិការថវិកា។

២-តារាងចំណូលថវិកា រួមបញ្ចូលនូវ៖

-តារាងចំណូលថវិកាថ្នាក់ជាតិ ចែកជាប្រភេទ ជំពូក គណនី អនុគណនី និងតាមក្រសួង ស្ថាប័ន

-តារាងចំណូលថវិការដ្ឋបាលរាជធានី ខេត្ត ចែកជាប្រភេទ ជំពូក គណនី អនុគណនី និងតាមរាជធានី ខេត្ត។

៣-តារាងចំណាយថវិកាដែលឆ្លុះបញ្ចាំងនូវលទ្ធផលស្ថាពរនៃចំណាយថវិកា ដូចមានចែងក្នុងចំណុចទី៤ផ្នែកទី១ ខាងលើ រួមបញ្ចូលនូវ៖

-តារាងចំណាយ បែងចែកទៅតាមក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល តាមប្រភេទចំណាយ

-តារាងចំណាយតាមកម្មវិធី

-តារាងចំណាយវិនិយោគ ដោយហិរញ្ញប្បទានក្នុងប្រទេស និងហិរញ្ញប្បទានក្រៅប្រទេស បែងចែកទៅតាមប្រភេទចំណាយដល់ក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល

-តារាងចំណាយឧបត្ថម្ភធនទៅគ្រឹះស្ថានសាធារណៈរដ្ឋបាល

-តារាងចំណាយថវិការដ្ឋបាលរាជធានី ខេត្ត(តាមប្រភេទចំណាយ តាមកម្មវិធី និងតាមរាជធានី ខេត្ត)។

៤-តារាងស្ថានភាពនិងលទ្ធផលហិរញ្ញវត្ថុ។

៥-តារាងចំណូល ចំណាយ ថវិកាឧបសម្ព័ន្ធ និងគណនីពិសេសរតនាគារ(ថ្នាក់ជាតិ)។

**មាត្រា៩៤ .-**

សេចក្តីព្រាងច្បាប់ទូទាត់ថវិកាដែលត្រូវដាក់ជូនរដ្ឋសភានិងព្រឹទ្ធសភា ត្រូវភ្ជាប់ជាមួយនូវឯកសារដូចខាងក្រោម៖

១-សេចក្តីថ្លែងហេតុនៃសេចក្តីព្រាងច្បាប់នេះ។

២-ឧបសម្ព័ន្ធស្តីពីរបាយការណ៍ហិរញ្ញវត្ថុ។

៣-ឧបសម្ព័ន្ធស្តីពីរបាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំតាមក្រសួង ស្ថាប័ននីមួយៗ អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលរាជធានី ខេត្ត។

៤-ឧបសម្ព័ន្ធស្តីពីឥណទានដែលបានមោឃភាពនិងឥណទានដែលអនុញ្ញាតឱ្យយោងទៅឆ្នាំបន្ទាប់ ក្នុងករណីដែលមានដូចមានចែងក្នុងមាត្រា៤៣នៃច្បាប់នេះ។

៥-ឧបសម្ព័ន្ធស្តីពីចំនួនបុគ្គលិកតាមក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

៦-ឧបសម្ព័ន្ធស្តីពីចំណូល ចំណាយថវិការដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។

ក្រៅពីឯកសារខាងលើនេះ រាជរដ្ឋាភិបាល អាចផ្តល់ឯកសារពាក់ព័ន្ធផ្សេងទៀត ដើម្បីភ្ជាប់ទៅនឹងសេចក្តីព្រាងច្បាប់ទូទាត់ថវិកា សម្រាប់ជាព័ត៌មានបន្ថែម ជូនរដ្ឋសភានិងព្រឹទ្ធសភា។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL



គេហទំព័រ ឯកសារមន្ត្រីសាធារណៈ - https://t.me/oa_channel

**មាត្រា៩៥ .-**

សេចក្តីព្រាងច្បាប់ទូទាត់ថវិកាត្រូវដាក់ឆ្លងគណៈរដ្ឋមន្ត្រី ពិនិត្យ និងសម្រេចនៅក្នុងអំឡុងពាក់កណ្តាលខែតុលា។ បន្ទាប់ពីបានពិនិត្យនិងសម្រេចរួចហើយ រាជរដ្ឋាភិបាលត្រូវបញ្ជូនសេចក្តីព្រាងច្បាប់ទូទាត់ថវិកានិងសំណុំឯកសារពាក់ព័ន្ធផ្សេងទៀត ដំណាលគ្នានឹងសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំជូនទៅរដ្ឋសភា ដើម្បីពិនិត្យនិងអនុម័ត មុននឹងបញ្ជូនសេចក្តីព្រាងច្បាប់នេះជូនទៅព្រឹទ្ធសភា យ៉ាងយូរនៅសប្តាហ៍ទី១នៃខែធ្នូ ដើម្បីពិនិត្យ ហើយឱ្យយោបល់មុនថ្ងៃទី២០ ខែធ្នូ និងប្រកាសឱ្យប្រើដោយព្រះរាជក្រម យ៉ាងយូរត្រឹមថ្ងៃទី៣១ ខែធ្នូ។

សេចក្តីព្រាងច្បាប់ទូទាត់ថវិកា ត្រូវផ្សព្វផ្សាយជាសាធារណៈក្នុងរយៈពេល១សប្តាហ៍ បន្ទាប់ពីបញ្ជូនទៅរដ្ឋសភា និងផ្សព្វផ្សាយជាសាធារណៈក្នុងរយៈពេល២សប្តាហ៍បន្ទាប់ពីច្បាប់ទូទាត់ថវិកានេះចូលជាធរមាន។

**មាត្រា៩៦ .-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបញ្ជូនរបាយការណ៍ហិរញ្ញវត្ថុទៅអាជ្ញាធរសវនកម្មជាតិ ក្នុងអំឡុងខែសីហា ដើម្បីឱ្យអាជ្ញាធរសវនកម្មជាតិពិនិត្យនិងផ្តល់មតិសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុនេះឱ្យបានរួចរាល់ ក្នុងអំឡុងពាក់កណ្តាលខែតុលា ស្របពេលដែលរាជរដ្ឋាភិបាលបញ្ជូនសេចក្តីព្រាងច្បាប់ទូទាត់ថវិកាទៅរដ្ឋសភា។

## ផ្នែកទី៣

## សិទ្ធិអំណាចនិងការទទួលខុសត្រូវ

**មាត្រា៩៧ .-**

គណនេយ្យករសាធារណៈទទួលបន្ទុកលើការទទួលនិងគ្រប់គ្រងចំណូល ទូទាត់ចំណាយ និងរក្សាទុកដាក់មូលនិធិ។ គណនេយ្យករសាធារណៈមានភារកិច្ចផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃការអនុវត្តថវិកាស្របតាមបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈនិងការគ្រប់គ្រងសាច់ប្រាក់។ មានតែគណនេយ្យករសាធារណៈទេ ដែលមានសិទ្ធិអំណាចក្នុងការអនុវត្តប្រតិបត្តិការនិងដោះស្រាយបញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងការគ្រប់គ្រងសាច់ប្រាក់។ គណនេយ្យករសាធារណៈទទួលបន្ទុកកាន់បញ្ជីគណនេយ្យនិងរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយធានាឱ្យបាននូវការគោរពគោលការណ៍និងបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ ព្រមទាំងធានាឱ្យបាននូវភាពស្មោះត្រង់នៃកិច្ចបញ្ជិកាគណនេយ្យ និងការគោរពតាមនីតិវិធីហិរញ្ញវត្ថុជាធរមានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ក្នុងដែនសមត្ថកិច្ចនេះ គណនេយ្យករសាធារណៈត្រូវមានការទទួលខុសត្រូវជាលក្ខណៈបុគ្គល និងជាប្រាក់កាស។

**មាត្រា៩៨ .-**

គណនេយ្យករសាធារណៈ ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ អាណាប័ក និងគណនេយ្យករសាធារណៈដទៃទៀត ត្រូវទទួលស្គាល់គណនេយ្យករសាធារណៈដែលបានទទួលការតែងតាំងរួច។

**មាត្រា៩៩ .-**

រាល់ការអនុវត្តចំណូលនិងចំណាយថវិការដ្ឋ ត្រូវធ្វើឡើងទៅតាមសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងបទប្បញ្ញត្តិជាធរមាន។

រាល់ការកត់ត្រាចំណូលនិងចំណាយថវិការដ្ឋ ត្រូវគោរពទៅតាមមាតិកាថវិកានិងប្លង់គណនេយ្យសាធារណៈ ហើយរាល់របាយការណ៍ចំណូលនិងចំណាយថវិការដ្ឋ និងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវមានតម្លាភាពនិងផ្សព្វផ្សាយជាសាធារណៈ ស្របតាមបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានសិទ្ធិចាត់មន្ត្រីក្រោមឱវាទចុះធ្វើអធិការកិច្ចលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួមទាំងរាល់កិច្ចប្រតិបត្តិការហិរញ្ញវត្ថុនិងគណនេយ្យ តាមក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងនីតិបុគ្គលសាធារណៈដទៃទៀត ដែលបានអនុវត្តប្រតិបត្តិការថវិការដ្ឋ ដើម្បីធានាការប្រមូលបាននូវព័ត៌មាននិងទិន្នន័យច្បាស់លាស់សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ទូទាត់ថវិកា។

## ជំពូកទី៦

## ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង សវនកម្មផ្ទៃក្នុង និងអធិការកិច្ចហិរញ្ញវត្ថុ

### ផ្នែកទី១

### ក្របខណ្ឌនិងដំណើរការ

**មាត្រា១០០.-**

ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ សហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំនិងដំណើរការប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងសវនកម្មផ្ទៃក្នុង ស្របតាមបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

វិធាននិងនីតិវិធីនៃការរៀបចំ និងដំណើរការប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងសវនកម្មផ្ទៃក្នុង ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា១០១.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសេនាធិការបច្ចេកទេសតែមួយរបស់រាជរដ្ឋាភិបាលនៅក្នុងកិច្ចការអធិការកិច្ចហិរញ្ញវត្ថុលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងមានភារកិច្ចធ្វើអធិការកិច្ចហិរញ្ញវត្ថុ នៅតាមក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងនីតិបុគ្គលដទៃទៀតដែលទទួលផលប្រយោជន៍ពីហិរញ្ញវត្ថុសាធារណៈ ដោយផ្អែកលើហានិភ័យ ករណីសង្ស័យ និងបណ្តឹង។

វិធាននិងនីតិវិធីនៃការធ្វើអធិការកិច្ចហិរញ្ញវត្ថុត្រូវកំណត់ដោយអនុក្រឹត្យ។

### ផ្នែកទី២

### សិទ្ធិអំណាចនិងការទទួលខុសត្រូវ

**មាត្រា១០២.-**

រដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័ន ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ ប្រធានសហគ្រាសសាធារណៈ និងនាយកគ្រឹះស្ថានសាធារណៈ



https://t.me/oa_channel

រដ្ឋបាល ត្រូវចាត់សវនករផ្ទៃក្នុងឱ្យធ្វើសវនកម្មលើអនុលោមភាពនិងប្រសិទ្ធភាពប្រតិបត្តិការនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់អង្គភាពក្រោមឱវាទស្របតាមបទប្បញ្ញត្តិជាធរមាន។

អង្គភាពរងសវនកម្មផ្ទៃក្នុង និងបុគ្គល ឬអង្គភាពពាក់ព័ន្ធ មានកាតព្វកិច្ចសហការ ផ្តល់ និងអនុញ្ញាតឱ្យចូលដល់ឯកសារ ព័ត៌មាន គណនីធនាគារ មន្ត្រី បុគ្គលិក ទ្រព្យសម្បត្តិ ប្រតិបត្តិការ និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ព្រមទាំងសហការអនុវត្តនីតិវិធីសវនកម្មនិងការងារផ្សេងទៀត ដើម្បីអភិវឌ្ឍមុខងារសវនកម្មផ្ទៃក្នុង ដោយគ្មានការរារាំង ប្រកបដោយការទទួលខុសត្រូវនិងប្រសិទ្ធភាពខ្ពស់ ស្របតាមបទប្បញ្ញត្តិគតិយុត្តជាធរមាន និងតាមការអនុញ្ញាតរបស់រដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័ន ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ ប្រធានសហគ្រាសសាធារណៈ និងនាយកគ្រឹះស្ថានសាធារណៈរដ្ឋបាលសាមី។

អង្គភាពរងសវនកម្មផ្ទៃក្នុងនៃក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ សហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវកែលម្អតាមអនុសាសន៍របស់សវនកម្មផ្ទៃក្នុងឱ្យបានទាន់ពេលកំណត់ ឱ្យមានប្រសិទ្ធភាពខ្ពស់ស្របតាមបទប្បញ្ញត្តិជាធរមាន។

**មាត្រា១០៣.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានសិទ្ធិចាត់មន្ត្រីក្រោមឱវាទចុះធ្វើអធិការកិច្ចហិរញ្ញវត្ថុលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួមមាន ការអនុវត្តចំណូលនិងចំណាយថវិការដ្ឋ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ស្របតាមវិធាននិងនីតិវិធីនៃការធ្វើអធិការកិច្ចហិរញ្ញវត្ថុជាធរមាន។

ស្ថាប័នរងអធិការកិច្ចហិរញ្ញវត្ថុមានកាតព្វកិច្ចសហការ ឆ្លើយបំភ្លឺ ផ្តល់លិខិតយុត្តិការ ទិន្នន័យ បញ្ជិកាគណនេយ្យ គណនីធនាគារ ទ្រព្យសម្បត្តិរដ្ឋ និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន គ្រប់គ្រាន់និងត្រឹមត្រូវ សម្រាប់ជាកម្មវត្ថុនៃការធ្វើអធិការកិច្ចហិរញ្ញវត្ថុ ដោយគ្មានការរារាំង ប្រកបដោយការទទួលខុសត្រូវនិងប្រសិទ្ធភាពខ្ពស់។

ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងនីតិបុគ្គលដទៃទៀតដែលទទួលផលប្រយោជន៍ពីហិរញ្ញវត្ថុសាធារណៈ ដែលរងអធិការកិច្ចហិរញ្ញវត្ថុ ត្រូវអនុវត្តតាមវិធានការអធិការកិច្ចហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាពខ្ពស់ស្របតាមបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី៧

## ទោសប្បញ្ញត្តិ

**មាត្រា១០៤.-**

ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ សហគ្រាសសាធារណៈ គ្រឹះសានសាធារណៈរដ្ឋបាល និងនីតិបុគ្គលដទៃទៀតដែលទទួលផលប្រយោជន៍ពីហិរញ្ញវត្ថុសាធារណៈ ដែលអនុវត្តមិនបានគោរពបទប្បញ្ញត្តិនៃច្បាប់នេះនិងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀតជាធរមាន ត្រូវទទួលរងនូវវិធានការហិរញ្ញវត្ថុដែលបេកំណត់ដោយអនុក្រឹត្យតាមការស្នើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

តេលេក្រាម ឯកសារមន្ត្រីសាធារណៈ - https://t.me/oa_channel

វិធានការហិរញ្ញវត្ថុ ចំពោះនីតិបុគ្គលដទៃទៀតដែលទទួលផលប្រយោជន៍ពីហិរញ្ញវត្ថុសាធារណៈ ដូចមានចែងខាងលើនេះ មិនមែនជាឧបសគ្គសម្រាប់ការចោទប្រកាន់និងការផ្តន្ទាទោសព្រហ្មទណ្ឌ ព្រមទាំងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមានឡើយ។

**មាត្រា១០៥ .-**

អ្នករាជការសាធារណៈនិងពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោតទាំងឡាយណា ដែលអនុវត្តបំពានលើបទប្បញ្ញត្តិនៃច្បាប់នេះ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀតជាធរមានក្នុងការអនុវត្តមុខងារនិងភារកិច្ចរបស់ខ្លួន ត្រូវទទួលទណ្ឌកម្មខាងរដ្ឋបាលស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។ ទណ្ឌកម្មខាងរដ្ឋបាលនេះ មិនមែនជាឧបសគ្គសម្រាប់ការចោទប្រកាន់និងការផ្តន្ទាទោសព្រហ្មទណ្ឌ ព្រមទាំងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមានឡើយ។

**មាត្រា១០៦ .-**

អ្នករាជការសាធារណៈនិងពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ដែលត្រូវបានរកឃើញថាបានធ្វើឱ្យបាត់បង់ប្រាក់កាសសាធារណៈឬខូចខាតទ្រព្យសម្បត្តិរដ្ឋ នោះតម្លៃនៃការបាត់បង់ឬការខូចខាត រួមទាំងការប្រាក់លើតម្លៃបាត់បង់ឬខូចខាតនោះនិងសំណងផ្សេងៗទៀត នឹងក្លាយជាបំណុលផ្ទាល់ចំពោះសាមីខ្លួននោះ ដែលត្រូវបំពេញកាតព្វកិច្ចសងនិងបង់ចូលថវិការដ្ឋវិញ។ ការទទួលខុសត្រូវជាប្រាក់កាសនេះ មិនមែនជាឧបសគ្គសម្រាប់ការចោទប្រកាន់និងការផ្តន្ទាទោសព្រហ្មទណ្ឌ ព្រមទាំងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមានឡើយ។

វិធាននិងនីតិវិធីពាក់ព័ន្ធនឹងការទទួលខុសត្រូវជាប្រាក់កាសនេះ ត្រូវកំណត់ដោយអនុក្រឹត្យតាមការស្នើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៨
## អន្តរប្បញ្ញត្តិ

**មាត្រា១០៧ .-**

រាជរដ្ឋាភិបាល ត្រូវរៀបចំនិងដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋានគតិយុត្ត ដើម្បីធានាការអនុវត្តជាមូលដ្ឋាននូវថវិកាសមិទ្ធកម្ម យ៉ាងយូរត្រឹមឆ្នាំ២០២៦។

**មាត្រា១០៨ .-**

ច្បាប់និងលិខិតបទដ្ឋានគតិយុត្តទាំងឡាយណា ដែលពាក់ព័ន្ធការអនុវត្តច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ និងច្បាប់វិសោធនកម្មពាក់ព័ន្ធទាំងឡាយ ដែលកំពុងអនុវត្ត ត្រូវបន្តអានុភាពអនុវត្ត រហូតដល់មានច្បាប់និងលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

## ជំពូកទី៩

## អវសានប្បញ្ញត្តិ

**មាត្រា១០៩ .-**

ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

ថ្ងៃ សុក្រ ៤រោច ខែ ផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មីនា ឆ្នាំ២០២៣

**ក្នុងព្រះបរមនាមនិងតាមព្រះរាជបញ្ជាគ្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

[illegible]

ស.រ.

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត បិន ឈិន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

## ឧបសម្ព័ន្ធនៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

## សទ្ទានុក្រម

### ក

**កម្មវិធី** សំដៅដល់ការប្រមូលផ្តុំនូវឥណទាននៃក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និង រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលរួមចំណែកដល់ការអនុវត្តគោលនយោបាយសាធារណៈដែលស្ថិតក្រោម ការគ្រប់គ្រងរបស់ខ្លួន។ កម្មវិធីនីមួយៗមានគោលបំណងច្បាស់លាស់ដែលអាចវាស់វែងបាន ដោយមានការកំណត់ សូចនាករជាក់លាក់។ កម្មវិធី ជាមូលដ្ឋានសម្រាប់កំណត់អនុកម្មវិធីនិងចង្កោមសកម្មភាព។

**ការខ្ចីប្រាក់ពីគេ** សំដៅដល់ការកៀរគរធនធានហិរញ្ញប្បទាន តាមរយៈការបោះផ្សាយលក់មូលបត្ររដ្ឋ និងការ ខ្ចីប្រាក់ពីស្ថាប័នហិរញ្ញវត្ថុ ពីដៃគូអភិវឌ្ឍ និងពីនីតិបុគ្គលផ្សេងទៀតស្របតាមបទប្បញ្ញត្តិជាធរមាន។

**ការធានារបស់រដ្ឋ** សំដៅដល់ការទទួលបំពេញកាតព្វកិច្ចហិរញ្ញវត្ថុជំនួស ក្នុងករណីភាគីដែលទទួលបានការ ធានាពីរដ្ឋ ពុំមានលទ្ធភាពទូទាត់សងទៅភាគីម្ខាងទៀតនៃកិច្ចព្រមព្រៀង។

**ការធ្វើបង្រួបបង្រួមគណនី** សំដៅដល់ការប្រមូលផ្តុំតួលេខនៃកិច្ចប្រតិបត្តិការហិរញ្ញវត្ថុនិងគណនេយ្យ របាយការណ៍ ថវិកា និងរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាពពាក់ព័ន្ធ ដោយគណនេយ្យកររតនាគារ ដើម្បីរៀបចំរបាយការណ៍ថវិកា និងរបាយការណ៍ហិរញ្ញវត្ថុរួមរបស់រដ្ឋ។

**ការឱ្យប្រាក់គេខ្ចី** សំដៅដល់ការផ្តល់ប្រាក់ឱ្យគេខ្ចីដោយប្រើថវិការដ្ឋ និង/ឬដោយប្រើហិរញ្ញប្បទានដែលរដ្ឋ ខ្ចីប្រាក់ពីគេ ស្របតាមបទប្បញ្ញត្តិជាធរមាន។

**ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម** សំដៅដល់ឯកសារយុទ្ធសាស្ត្រ ដែលផ្តល់នូវការប៉ាន់ស្មាន ពីធនធាននិងបន្ទុកថវិការដ្ឋ កំណត់ជំហរគោលនយោបាយថវិកា កំណត់ពិតានចំណាយថវិកាថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ព្រមទាំងកំណត់ពិតានតម្រូវការហិរញ្ញប្បទាន និងវាយតម្លៃហានិភ័យហិរញ្ញវត្ថុសាធារណៈ សម្រាប់ រយៈពេលមធ្យម ដោយផ្អែកលើមូលដ្ឋាននៃទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ច និងអាទិភាពគោលនយោបាយរបស់ រាជរដ្ឋាភិបាល ដើម្បីធានាបាននូវចីរភាពហិរញ្ញវត្ថុសាធារណៈ។

**ក្របខ័ណ្ឌថវិការយៈពេលមធ្យម** សំដៅដល់ការរៀបចំឱ្យមានជាយន្តការស្ថាប័នសម្រាប់ការធ្វើ អាទិភាវូបនីយកម្ម ដើម្បីបង្ហាញអំពីអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាលដោយដាក់ចេញនូវពិតានចំណាយ និងសនិទានកម្មសម្រាប់រយៈពេលមធ្យម ជូនក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្របខ័ណ្ឌថវិការយៈពេល មធ្យម ផ្សារភ្ជាប់ទៅនឹងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម និងផែនការយុទ្ធសាស្ត្រថវិកា តាមរយៈការធ្វើ សមាហរណកម្មផ្នែកគោលនយោបាយ ការរៀបចំផែនការ និងការប៉ាន់ស្មានថវិកាសម្រាប់រយៈពេលមធ្យម៣(បី) ឆ្នាំ។

**ក្រសួង** សំដៅដល់ក្រសួង ដែលត្រូវបង្កើតឡើងដោយអនុលោមតាមច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃ គណៈរដ្ឋមន្ត្រី និងដឹកនាំដោយសមាជិករាជរដ្ឋាភិបាលដែលជាអាណាប័កដើមខ្សែនៃថវិការបស់ក្រសួងសាមី។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL



https://t.me/oa_channel

គ

**គណនីទោលរតនាគារ** សំដៅដល់ប្រព័ន្ធនៃការគ្រប់គ្រង និងប្រមូលផ្តុំគណនីធនាគារ ឬសាច់ប្រាក់របស់រាជរដ្ឋាភិបាល ដែលស្ថិតក្រោមរចនាសម្ព័ន្ធនិងការគ្រប់គ្រងតែមួយគត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈគណនេយ្យករសាធារណៈ។ គណនីទោលរតនាគារ ត្រូវបានប្រើប្រាស់ក្នុងការប្រមូលផ្តុំធនធានរបស់រដ្ឋ សម្រាប់ធានាដល់ប្រសិទ្ធភាពនៃការទូទាត់ចំណាយរបស់រដ្ឋ។

**គណនេយ្យកររតនាគារ** សំដៅដល់គណនេយ្យករសាធារណៈដែលបំពេញមុខងារនៅអគ្គនាយកដ្ឋានរតនាគារជាតិ។ គណនេយ្យកររតនាគារ រួមមាន គណនេយ្យកររតនាគារកណ្តាល និងគណនេយ្យកររតនាគាររាជធានីខេត្ត។ គណនេយ្យកររតនាគារទទួលបន្ទុកលើការងារហិរញ្ញវត្ថុនិងគណនេយ្យរបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងមានមុខងារធ្វើមជ្ឈការតួលេខនៃកិច្ចប្រតិបត្តិការហិរញ្ញវត្ថុនិងគណនេយ្យ និងរបាយការណ៍ថវិកានិងហិរញ្ញវត្ថុរបស់អង្គភាពដទៃទៀត ដើម្បីរៀបចំរបាយការណ៍ថវិកានិងរបាយការណ៍ហិរញ្ញវត្ថុរួមរបស់រដ្ឋ។

**គណនេយ្យករសាធារណៈ** សំដៅដល់ភ្នាក់ងាររបស់រដ្ឋដែលទទួលបន្ទុកលើកិច្ចការទទួលនិងគ្រប់គ្រងចំណូល ទូទាត់ចំណាយ រក្សាទុកដាក់និងគ្រប់គ្រងសាច់ប្រាក់ កាន់បញ្ជីគណនេយ្យ និងរៀបចំរបាយការណ៍ថវិកានិងរបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋ។ គណនេយ្យករសាធារណៈ រួមមាន គណនេយ្យកររតនាគារ គណនេយ្យករប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល គណនេយ្យករថវិកាឧបសម្ព័ន្ធ គណនេយ្យករគណនីពិសេសរតនាគារ និងគណនេយ្យករដែលអនុវត្តគណនេយ្យនៃថវិការដ្ឋដទៃទៀត។

**គណនេយ្យភាព** សំដៅដល់ការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ និងនីតិបុគ្គលដទៃទៀត ចំពោះមុខងារ និងភារកិច្ចពាក់ព័ន្ធនឹងហិរញ្ញវត្ថុសាធារណៈ តាមរយៈប្រព័ន្ធរបាយការណ៍។ ភ្នាក់ងារអនុវត្តថវិកាជាតិ ដែលមានអាណាប័កនិងគណនេយ្យករសាធារណៈ ត្រូវទទួលខុសត្រូវចំពោះសេចក្តីសម្រេចចិត្តរបស់ខ្លួន ក្រោមសិទ្ធិអំណាចដែលផ្តល់ដោយច្បាប់។

ច

**ចីរភាព** សំដៅដល់តុល្យភាពរវាងចំណូលនិងចំណាយ ដែលត្រូវស្ថិតនៅក្នុងទំហំដែលថវិកាអាចទ្រទ្រង់បាន។ ក្នុងករណីដែលមានឱនភាពថវិកា ការធ្វើហិរញ្ញប្បទាន ឬការខ្ចីបំណុល ត្រូវគិតគូរនៅក្នុងកម្រិតមួយ ដែលអាចទូទាត់សងវិញបានក្នុងរយៈពេលវែង។

**ចំណូលសារពើពន្ធក្នុងស្រុក** សំដៅដល់ចំណូលទទួលបានពីការបង់ពន្ធអាករនិងទោសទណ្ឌពីការអនុវត្តច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ។

**ចំណូលសារពើពន្ធលើពាណិជ្ជកម្មអន្តរជាតិ** សំដៅដល់ចំណូលទទួលបានពីការបង់ពន្ធ អាករ និងកម្រៃផ្សេងៗលើការនាំចូលនិងការនាំចេញ។

ដ

**ដៃគូអភិវឌ្ឍ** សំដៅដល់ប្រទេសឬស្ថាប័នដែលផ្តល់ហិរញ្ញប្បទានក្នុងទម្រង់ជាឥណទាន ហិរញ្ញប្បទានឥតសំណង ឬជំនួយបច្ចេកទេសដល់ព្រះរាជាណាចក្រកម្ពុជា ក្នុងគោលដៅអភិវឌ្ឍសង្គម សេដ្ឋកិច្ច និងការកសាងហេដ្ឋារចនាសម្ព័ន្ធ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ត

**តម្លាភាព** សំដៅដល់រាល់ច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងព័ត៌មាន គោលការណ៍ និងនីតិវិធីទាំងឡាយពាក់ព័ន្ធនឹងថវិកា ទាំងហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ ដែលត្រូវផ្សព្វផ្សាយទាន់ពេល ជូនដល់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ និងសាធារណជន ស្របតាមការកំណត់នៃបទប្បញ្ញត្តិជាធរមាន។

**តុល្យភាពថវិកា** សំដៅដល់តុល្យភាពរវាងធនធាននិងបន្ទុកថវិកាក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំនិងច្បាប់ហិរញ្ញវត្ថុកែតម្រូវ។

**តុល្យភាពហិរញ្ញវត្ថុ** សំដៅដល់តុល្យភាពរវាងធនធាននិងបន្ទុករបស់រដ្ឋក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំនិងច្បាប់ហិរញ្ញវត្ថុកែតម្រូវ។ តុល្យភាពហិរញ្ញវត្ថុត្រូវបានធានាតាមរយៈទំនាក់ទំនងរវាងតុល្យភាពថវិកានិងការធ្វើហិរញ្ញប្បទានរបស់រដ្ឋ។ ក្នុងករណីមានអតិរេកថវិកា រដ្ឋអាចប្រើប្រាស់អតិរេកថវិកាសម្រាប់ដោះស្រាយតម្រូវការហិរញ្ញប្បទានឬក្នុងករណីមានឱនភាពថវិកា រដ្ឋត្រូវប្រើប្រាស់ប្រភពហិរញ្ញប្បទានសម្រាប់បំពេញឱនភាពថវិកា។

## ទ

**ទ្រព្យសកម្ម** សំដៅដល់ធនធាននានាដែលអង្គភាពគ្រប់គ្រង ជាលទ្ធផលនៃព្រឹត្តិការណ៍ពីអតីតកាល ហើយអង្គភាពរំពឹងទទួលបានអត្ថប្រយោជន៍សេដ្ឋកិច្ចឬសក្តានុពលសេវានាពេលអនាគតពីធនធានទាំងនោះ។

**ទ្រព្យសកម្មហិរញ្ញវត្ថុ** សំដៅដល់ទ្រព្យសកម្មទាំងឡាយណាដែលជា (ក) សាច់ប្រាក់ (ខ) ឧបករណ៍មូលធនរបស់អង្គភាពផ្សេងទៀត និង(គ) សិទ្ធិតាមកិច្ចសន្យាមួយដើម្បីទទួលបានសាច់ប្រាក់ឬទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងទៀត ឬដោះដូរឧបករណ៍ហិរញ្ញវត្ថុជាមួយអង្គភាពដទៃដើម្បីទទួលបានផលចំណេញ។

## ប

**ប្រធានកម្មវិធី** សំដៅដល់ថ្នាក់ដឹកនាំ ដែលត្រូវតែងតាំងដោយរដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័ន ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលជាអាណាប័កដើមខ្សែ ដើម្បីទទួលខុសត្រូវលើការរៀបចំថវិកា ការសម្របសម្រួល ការតាមដាន និងការជំរុញកិច្ចប្រតិបត្តិការនានាក្នុងកម្រិតកម្មវិធី រួមទាំងការអនុវត្តថវិកា ដើម្បីសម្រេចបាននូវសមិទ្ធកម្មតាមការគ្រោងទុក។

**ប្រធានអង្គភាពថវិកា** សំដៅដល់ប្រតិបត្តិករទទួលខុសត្រូវលើកិច្ចប្រតិបត្តិការនានាក្នុងក្របខ័ណ្ឌសិទ្ធិអំណាចនិងការទទួលខុសត្រូវរបស់ខ្លួន រួមទាំងការរៀបចំថវិកា ការអនុវត្តថវិកា និងសមិទ្ធកម្មដែលបានគ្រោងចំពោះមុខប្រធានកម្មវិធី និងអាណាប័កដើមខ្សែ។

**ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង** សំដៅដល់វិធានការឬដំណើរការត្រួតពិនិត្យដែលបានរៀបចំនិងអនុវត្តដោយអង្គភាពផ្ទាល់ ដើម្បីផ្តល់ការធានាសមស្របក្នុងគោលបំណងសម្រេចបាននូវប្រសិទ្ធភាពនិងសក្តិសិទ្ធភាពនៃប្រតិបត្តិការ ភាពជឿទុកចិត្តបាននិងសុចរិតភាពនៃព័ត៌មាន ព្រមទាំងអនុលោមភាពទៅនឹងគោលការណ៍ ផែនការ នីតិវិធី និងបទប្បញ្ញត្តិជាធរមាន។



https://t.me/oa_channel

**ប្រសិទ្ធភាព** សំដៅដល់ថវិកាដែលត្រូវបែងចែកត្រឹមត្រូវនិងចំអាទិភាពគោលនយោបាយនៅក្នុងទំហំសមស្រប ហើយចំណាយត្រូវអនុវត្តដោយធានាបានតម្លៃនៃលុយ។

៣

**ពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត** សំដៅដល់សមាជិកព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងពលរដ្ឋដែលទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ដើម្បីបំពេញមុខងារសាធារណៈដទៃទៀត។

ភ

**ភាពជាអាជ្ញា** សំដៅដល់ច្បាប់ស្តីពីហិរញ្ញវត្ថុ ដែលតម្រូវឱ្យគោរពដាច់ខាតនិងពុំអាចបំពានដោយស្ថាប័នសាធារណៈណាមួយបានឡើយ ហើយច្បាប់នេះក៏មានឧត្តមភាពទៅលើច្បាប់នានាផងដែរ ខាងផ្នែកទិដ្ឋភាពហិរញ្ញវត្ថុសាធារណៈ។

**ភាពជឿទុកចិត្តបាន** សំដៅដល់ព័ត៌មានឬទិន្នន័យអំពីថវិកា ដែលត្រូវមានភាពពេញលេញគ្រប់ជ្រុងជ្រោយ ត្រឹមត្រូវនិងមានសង្គតិភាព។ ទន្ទឹមនេះ ការពណ៌នាអំពីព័ត៌មានហិរញ្ញវត្ថុនិងមិនមែនហិរញ្ញវត្ថុ ក៏តម្រូវឱ្យមានភាពស្មោះត្រង់ និងសុចរិត មិនបំផ្លើស ឬលាក់លៀមនូវចំណូលឬចំណាយណាមួយឡើយ។

រ

**រដ្ឋបាលថ្នាក់ក្រោមជាតិ** សំដៅដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដែលជានីតិបុគ្គលសាធារណៈហើយមានស្វ័យភាពក្នុងការគ្រប់គ្រងរដ្ឋបាលរបស់ខ្លួនស្ថិតក្រោមដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានីមួយៗ ដែលមានសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្ត លើកលែងតែករណីមានបញ្ញត្តិដោយឡែកដែលចែងផ្សេងពីនេះ។

**រដ្ឋបាលថ្នាក់ជាតិ** សំដៅដល់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងមន្ទីរជំនាញក្រោមឱវាទ លើកលែងតែករណីមានបញ្ញត្តិដោយឡែកដែលចែងផ្សេងពីនេះ។

**របៀបវារៈគោលនយោបាយ** សំដៅដល់យុទ្ធសាស្ត្រសម្រាប់សម្រេចចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ដែលឆ្លុះបញ្ចាំងក្នុងផែនការរដ្ឋ ដែលរួមមានផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងគោលនយោបាយតាមវិស័យ និងអនុវិស័យរបស់ក្រសួង ស្ថាប័ន។

**រយៈពេលមធ្យម** សំដៅដល់រយៈពេលដែលមិនតិចជាង៣(បី)ឆ្នាំ និងមិនលើសពី៥(ប្រាំ)ឆ្នាំ។

វ

**វិន័យហិរញ្ញវត្ថុសាធារណៈ** សំដៅដល់ការគោរពនិងអនុវត្តតាមគោលការណ៍ បទប្បញ្ញត្តិ និងនីតិវិធីជាធរមានក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងការគោរពតាមលក្ខខណ្ឌនៃសូចនាករសំខាន់ៗកំណត់ក្នុងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការរៀបចំក្របខ័ណ្ឌថវិកា និងពង្រឹងប្រសិទ្ធភាពនិងវិន័យក្នុងការអនុវត្ត ដើម្បីធានានូវចីរភាពហិរញ្ញវត្ថុសាធារណៈ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។

**វិសាលភាព** សំដៅដល់ចំណូលនិងចំណាយ ដែលជាកម្មវត្ថុត្រូវបង្ហាញអំពីមូលដ្ឋានគិតគូរលម្អិតច្បាស់លាស់[illegible]ច្បាប់ហិរញ្ញវត្ថុ។ ចំណូលត្រូវបង្ហាញប្រភេទធំៗ រីឯចំណាយត្រូវបង្ហាញអំពីគោលបំណងនិង

គោលដៅនៃការប្រើប្រាស់ឥណទានថវិកានិងមានមុខសញ្ញាប្រើប្រាស់ច្បាស់លាស់ ព្រមទាំងស្ថិតនៅក្នុងកម្រិតអតិបរមាកំណត់។ ក្នុងន័យនេះ ថវិកាចាំបាច់ត្រូវបង្ហាញច្បាស់លាស់អំពីគោលបំណងនិងគោលដៅនៃសកម្មភាពការងារសាធារណៈទាំងឡាយ ដែលតម្រូវឱ្យប្រមូលចំណូលទាំងអស់ និងទូទាត់ចំណាយទាំងអស់របស់ថវិការដ្ឋ។

ស

**សកលភាព** សំដៅដល់គ្រប់ប្រភេទចំណូលទាំងអស់ ដែលត្រូវប្រើប្រាស់សម្រាប់រាល់មុខចំណាយដោយគ្មានលក្ខខណ្ឌ។ គ្រប់ប្រភេទចំណូលទាំងអស់ ត្រូវប្រមូល កត់ត្រា និងបង់ទាំងស្រុងចូលគណនីទោលរតនាគារ និងមិនត្រូវយកទៅកាត់កងដោយត្រង់ជាមួយចំណាយណាមួយឡើយ។

**សមិទ្ធកម្ម** សំដៅដល់លទ្ធផលនៃការអនុវត្តថវិកាទាំងហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ ដែលអាចវាស់វែងបានក្នុងទម្រង់ជាសូចនាករគន្លឹះៗ សម្រាប់ជាមូលដ្ឋាននៃការវាយតម្លៃភាពសន្សំសំចៃ ប្រសិទ្ធភាព និងសក្តិសិទ្ធិភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

**សវនកម្មផ្ទៃក្នុង** សំដៅដល់សកម្មភាពពិគ្រោះយោបល់និងការធានាអះអាងដោយឯករាជ្យ មិនលំអៀង ដោយប្រើអភិក្រមជាប្រព័ន្ធ មានជំនាញត្រឹមត្រូវក្នុងការវាយតម្លៃ និងបង្កើនប្រសិទ្ធភាពលើដំណើរការគ្រប់គ្រងហានិភ័យ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងអភិបាលកិច្ច ដើម្បីបន្ថែមតម្លៃនិងធ្វើឱ្យប្រតិបត្តិការប្រសើរឡើងដែលអនុញ្ញាតឱ្យអង្គភាពសម្រេចគោលបំណងតាមការកំណត់។

**សហគ្រាសសាធារណៈ** សំដៅដល់នីតិបុគ្គលដែលមានស្វ័យភាពហិរញ្ញវត្ថុដែលមានដើមទុនទាំងអស់ឬភាគច្រើនជារបស់រដ្ឋ។ ក្រៅពីបទប្បញ្ញត្តិដែលមានចែងនៅក្នុងច្បាប់នេះ ការគ្រប់គ្រងសហគ្រាសសាធារណៈ ជាកម្មវត្ថុនៃការកំណត់ដោយច្បាប់ដែលមានការពាក់ព័ន្ធផ្សេងទៀត។

**ស្ថាប័ន** សំដៅដល់ស្ថាប័នក្រៅពីក្រសួង ដែលបង្កើតឡើងដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឬបង្កើតឡើងដោយច្បាប់ដែលដឹកនាំដោយប្រធានជាអាណាប័កដើមខ្សែនៃថវិការបស់ស្ថាប័នសាមី។

ហ

**ហិរញ្ញវត្ថុសាធារណៈ** សំដៅដល់ធនធាននិងបន្ទុករបស់រដ្ឋ ដែលរួមមាន ចំណូល ចំណាយ ទ្រព្យសកម្ម និងទ្រព្យអកម្ម ដែលរដ្ឋត្រូវគ្រប់គ្រង ប្រើប្រាស់ និងចាត់ចែងឱ្យមានចីរភាព ស្ថិរភាព និងប្រសិទ្ធភាពក្នុងរយៈពេលមធ្យម និងវែងក្នុងគោលដៅអភិវឌ្ឍសង្គម សេដ្ឋកិច្ចរបស់ប្រទេស។

អ

**អ្នករាជការសាធារណៈ** សំដៅដល់ (ក) បុគ្គលដែលបម្រើការងារនៅក្នុងស្ថាប័ននីតិប្បញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ ឬស្ថាប័នតុលាការដែលត្រូវបានតែងតាំងដោយលិខិតបទដ្ឋានគតិយុត្ត ទោះជាអចិន្ត្រៃយ៍ ឬជាបណ្តោះអាសន្នក្តី ទោះជាបានទទួល ឬមិនបានទទួលប្រាក់ឈ្នួលក្តី ដោយមិនគិតពី ឋានៈ អាយុរបស់បុគ្គលនោះឡើយ (ខ)បុគ្គលផ្សេងទៀត ដែលធ្វើការក្នុងមុខងារសាធារណៈ រួមទាំងទីភ្នាក់ងារសាធារណៈ ឬសហគ្រាសសាធារណៈ ព្រមទាំងស្ថាប័នសាធារណៈដទៃទៀត ដែលមានចែងនៅក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL



គេហទំព័រ ឯកសារមន្ត្រីសាធារណៈ - https://t.me/oa_channel

**អង្គភាពត្រួតពិនិត្យថវិកា** សំដៅដល់អង្គភាពដែលត្រូវបានបង្កើតឡើងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ដាក់ឱ្យនៅអមក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ឬអាចជាអង្គភាពដែលនៅកៀក ឬស្ថិតនៅកម្រិតអនុវត្តថវិកា ដែលត្រូវបានផ្តល់ប្រតិភូកម្មដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីបំពេញមុខងារត្រួតពិនិត្យហិរញ្ញវត្ថុ ត្រួតពិនិត្យការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ និងត្រួតពិនិត្យនិងជំរុញការប្រមូលចំណូលមិនមែនសារពើពន្ធ។

**អង្គភាពថវិកា** សំដៅដល់អង្គភាពដែលក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិសាមី បានផ្តល់អាណត្តិកិច្ចច្បាស់លាស់ក្នុងការអនុវត្តសកម្មភាពការងារដើម្បីបង្កើតបានជាលទ្ធផលជាក់លាក់ អាចវាស់វែងបាន និងរួមចំណែកក្នុងការសម្រេចគោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងវង្ងង់ឥណទានថវិកាដែលបានវិភាជជូន។ អង្គភាពថវិកាអាចជាអគ្គនាយកដ្ឋាន ឬអង្គភាពដែលមានថ្នាក់ស្មើ ឬកម្រិតប្រហាក់ប្រហែលអគ្គនាយកដ្ឋាន ឬនាយកដ្ឋាន ហើយមានរចនាសម្ព័ន្ធគ្រប់គ្រងច្បាស់លាស់ ព្រមទាំងមានទំហំការងារ ចំនួនបុគ្គលិក និងទំហំថវិកាសមស្រប។

**អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ** សំដៅដល់អង្គភាពតែមួយគត់ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាណាប័កដើមខ្សែរបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលមានតួនាទី និងភារកិច្ចដឹកនាំ ណែនាំ គាំទ្រ និងសម្របសម្រួលជាមួយគ្រប់អង្គភាពថវិកា ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ការរៀបចំថវិកាប្រចាំឆ្នាំ ការអនុវត្តថវិកា ការពិនិត្យ និងការតាមដានការអនុវត្តថវិកា និងបូកសរុបរបាយការណ៍។ អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុអាចជាអគ្គលេខាធិការដ្ឋាន ជាអគ្គនាយកដ្ឋានឬជានាយកដ្ឋានឬទីចាត់ការឬការិយាល័យទទួលបន្ទុកការងារហិរញ្ញវត្ថុ ដែលទទួលបន្ទុកការងារថវិកានិងហិរញ្ញវត្ថុរបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**អង្គភាពរដ្ឋមិនមានបុគ្គលភាពគតិយុត្ត** សំដៅដល់អង្គភាពចំណុះក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវប្រគល់មុខងារ ឬបង្កើតឱ្យអនុវត្តថវិកាឧបសម្ព័ន្ធ តាមលក្ខណៈវិនិច្ឆ័យដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

**អង្គភាពសាធារណៈប្រហាក់ប្រហែល** សំដៅដល់អង្គភាពសាធារណៈ ក្រៅពីក្រសួង និងស្ថាប័ន ហើយពុំមែនជាអង្គភាពក្រោមឱវាទរបស់ក្រសួងឬស្ថាប័នណាមួយឡើយ។ អង្គភាពសាធារណៈប្រហាក់ប្រហែល ត្រូវបង្កើតដោយលិខិតបទដ្ឋានគតិយុត្តជាធរមាន និងទទួលហិរញ្ញប្បទានទាំងស្រុងឬមួយផ្នែកនៃថវិកាជាតិ ដែលដឹកនាំដោយប្រធានជាអាណាប័កដើមខ្សែនៃថវិការបស់សាមីអង្គភាពសាធារណៈ។

**អង្គភាពអនុវត្តថវិកា** សំដៅដល់អង្គភាពថវិកា និងអង្គភាពផ្សេងៗទៀតចំណុះក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលអនុវត្តថវិកា។

**អធិការកិច្ចហិរញ្ញវត្ថុ** សំដៅដល់ការត្រួតពិនិត្យ ស្រាវជ្រាវ អង្កេត និងផ្ទៀងផ្ទាត់លើកិច្ចប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ ព្រមទាំងការអនុវត្តលិខិតគតិយុត្តពាក់ព័ន្ធនឹងហិរញ្ញវត្ថុសាធារណៈ ដើម្បីចូលរួមធានាគណនេយ្យភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**អាណាប័ក** សំដៅដល់អ្នកមានសិទ្ធិអំណាចគ្រប់គ្រាន់តាមច្បាប់ក្នុងការបញ្ជាកិច្ចប្រតិបត្តិការចំណូល និងចំណាយថវិការបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងវង្ស់ឥណទានថវិការបស់ខ្លួន។ អាណាប័ក រួមមាន អាណាប័កដើមខ្សែ អាណាប័កផ្ទេរសិទ្ធិ និងអាណាប័កជំនួស។

**អាណាប័កដើមខ្សែ** សំដៅដល់រដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័ន ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក និងមេឃុំ ដែលមានសិទ្ធិពេញលេញក្នុងការបញ្ជាចំណូល និងចំណាយថវិកាដោយខ្លួនឯងផ្ទាល់ ដោយត្រូវគោរពទៅតាមព្រំដែននៃសិទ្ធិអំណាច និងមុខងាររបស់ខ្លួន។

**អាណាប័កជំនួស** សំដៅដល់ថ្នាក់ដឹកនាំក្រោមឱវាទ ដែលទទួលបានការចាត់តាំងពីអាណាប័កដើមខ្សែឬអាណាប័កផ្ទេរសិទ្ធិ ដើម្បីប្រគល់សិទ្ធិជំនួសខ្លួនឬដើម្បីផ្ទេរសិទ្ធិ ដោយផ្អែកលើបទបញ្ជាគណនេយ្យសាធារណៈ ក្នុងពេលដែលអាណាប័កដើមខ្សែឬអាណាប័កផ្ទេរសិទ្ធិ អវត្តមាន ឬមានធុរៈ។

**អាណាប័កផ្ទេរសិទ្ធិ** សំដៅដល់ប្រធានអង្គភាពថវិកាក្រោមឱវាទ ដែលបានទទួលសិទ្ធិពីអាណាប័កដើមខ្សែ សម្រាប់អនុវត្តកិច្ចប្រតិបត្តិការថវិកាក្នុងវង្វង់ឥណទានថវិកាដែលវិភាជជូន ដើម្បីសម្រេចសមិទ្ធកម្មតាមការគ្រោងទុក។

ង

**ឯកត្តភាព** សំដៅដល់គ្រប់ចំណូលនិងចំណាយទាំងអស់ ដែលត្រូវគ្រោងព្រមគ្នា នៅក្នុងឯកសារតែមួយ គឺច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។ នៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឯកត្តភាពក៏សំដៅផងដែរដល់ប្រព័ន្ធថវិកាតែមួយ ដែលមានការឯកភាពនិងមានសង្គតិភាព ហើយត្រូវអនុវត្តតាមយន្តការ ដែលមានក្របខ័ណ្ឌតែមួយច្បាស់លាស់។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *



គេហទំព័រ ឯកសារច្បាប់សាធារណៈ - https://t.me/oa_channel